# ដំណោះស្រាយបញ្ហា
# រវាង
# មាតាបិតា និង កូន

*សម្តែងដោយ*

ព្រះតេជគុណបណ្ឌិត CHEKINDA

*ប្រែសម្រួល និង រៀបរៀងដោយ*

*ភិក្ខុ* **ស៊ុយ សុវណ្ណ**

**បោះពុម្ពលើកទី១**

.................................

**ការផ្សាយរបស់**

**វត្តអម្ពវនារាម** (*ក្រយា*), *ស្រុកសន្ទុក*, *ខេត្តកំពង់ធំ*

*ឧបត្ថម្ភបោះពុម្ពដោយ*

**ពុទ្ធបរិស័ទទូទៅ**

**២៥៥៣**

# Aspect of Two Straight Lines

Preached by

Venerable Dr. Ashin Chekinda

Translated and prepared by
Venerable Suy Sovann (Pannavaro)

First Edition

.......................................

A Publication of

Wat Ambavanarama (Kraya)/ Santuk District/
Kg. Thom Province/Cambodia

Sponsored by:

...........................................

2553

## សេចក្តីផ្តើម

Introduction

### ផ្នែកទី១

Part I:

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

ខ្ញុំអញ្ជើញមាតាបិតា និងកូនទាំងឡាយមកជួបគ្នានៅវត្តខ្ញុំ ពីព្រោះ ពេលខ្លះពួកគេមិនមានឱកាសបង្ហាញពីការនិយាយស្តី និងអារម្មណ៍របស់ពួកទេ។ មាតាបិតាទាំងឡាយមានអារម្មណ៍ ចំពោះកូនទាំងឡាយ។ ទន្ទឹមនេះដែរ ជួនកាលកូនទាំងឡាយត្រូវតែលាក់-បាំងនូវអារម្មណ៍របស់គេ ព្រោះពួកគេមិនចង់តបតជាមួយឪពុក-ម្តាយរបស់គេ។ ពួកគេត្រូវបញ្ចេញនូវអារម្មណ៍ទាំងអស់នោះនៅទី-នេះ។

I make parents and children to meet at my monastery because sometimes they have no chance to express their words and feelings. Parents have their feelings to children. Likewise, children sometimes have to conceal their feelings as they don’t want to resort back to their parents. Those feelings are to be expressed here.

គោលបំណងជាចម្បង គឺថា នៅពេលខ្ញុំបានទៅទស្សនា នៅប្រទេសដទៃជាច្រើន ខ្ញុំឃើញទំនាក់ទំនងរវាងមាតាបិតា និងកូន ភាគច្រើនមិនល្អសោះ។ ចំនួនពុទ្ធសាសនិកមានតិចតួចណាស់នៅប្រទេសទាំងនោះ។ ហើយពួកគេមិនអាចបង្កើតការទំនាក់ទំនងល្អ ជាមួយកូនពួកគេ ដូចជាពុទ្ធសាសនិក ដែលទស្សនវិស័យសាសនា និងក្រមសីលធម៌របស់ពួកគេខុសពីអ្នកទាំងនោះ។

The purpose…..Globally… when I visited other countries, I found the relationships between most of the parents and children are not good. The number of the Buddhists is few in those countries. And parents cannot make a good relationship with their children like Buddhists whose religious outlook and moral grounds are different from them.

ដូច្នេះ មាតាបិតាបានអនុញ្ញាតឱ្យកូនរបស់គេ ចេញពីផ្ទះនៅអាយុ ១៨ ឆ្នាំ ដើម្បីដឹកនាំជីវិតរបស់គេផ្ទាល់។ ពួកគេឱ្យកូនរស់នៅយោងទៅតាមបទបញ្ញត្តិ និងច្បាប់ទាំងឡាយ។ តាមទស្សនៈខ្ញុំ, ខ្ញុំមិនចង់ឱ្យទំនៀមទម្លាប់ទាំងនោះ មកចាក់គ្រឹះបន្តិចម្តងៗ នៅក្នុងប្រទេសរបស់យើងឡើយ។

So, the parents let their children leave home at the age of eighteen to lead their own lives. They treat their children according to rules and laws. In my

opinion, I do not want such customs to gradually take root in our country.

លើសពីនេះទៀត ខ្ញុំដឹងថា មានសេចក្ដីស្រឡាញ់គ្នាទៅវិញទៅមក រវាងមាតាបិតា និងកូន។ មិនមានបុគ្គលណាមួយ ដែលមាតាបិតាស្រឡាញ់ដូចកូនរបស់ពួកគេឡើយ។ ចំពោះកូនវិញ ពួកគេដឹងនូវគុណដែលបានជំពាក់បំណុលមាតាបិតារបស់គេ។ ហើយមាតាបិតាគឺជាបុគ្គលជាទីស្រឡាញ់សម្រាប់ពួកគេតែមួយគត់។ ប៉ុន្តែ នៅមានបញ្ហាខ្លះៗរវាងពួកគេ។ ខ្ញុំដឹងបញ្ហាទាំងអស់នេះ នៅពេលដែលខ្ញុំបានបើកមណ្ឌលវិបស្សនាដើម្បីអប់រំក្មេងៗ។ ខ្ញុំស្ដាប់នូវអ្វីដែលពួកគេនិយាយទាំងភាពតានតឹងមកកាន់ខ្ញុំ។ ខ្ញុំស្ដាប់នូវអារម្មណ៏ក្មេងៗអាយុថ្នាក់ទី៤ ទី៥ ទី៦ និងរហូតដល់ថ្នាក់សាកលវិទ្យាល័យ។ ដូច្នេះខ្ញុំដឹងនូវអារម្មណ៏របស់គេ ទាក់ទងនឹងមាតាបិតារបស់គេ។ ឪពុកម្ដាយខ្លះក៏បានអញ្ជើញមកវត្តខ្ញុំ ឬទូរស័ព្ទមកខ្ញុំ។ ហើយពួកគេប្រាប់ខ្ញុំពីអារម្មណ៏របស់ពួកគេ ទាក់ទងនឹងកូនៗរបស់គេ។ បន្ទាប់ពីការពិភាក្សាជាមួយខ្ញុំ ភាពតានតឹងទាំងឡាយរវាងពួកគេ ក៏រលាយបាត់ទៅ។ ប៉ុន្តែ វាមិនបានយូរប៉ុន្មានឡើយ។ ភាពតានតឹងក៏កើតឡើងសាជាថ្មី នៅពេលពួកគេទៅដល់ផ្ទះភ្លាម។ ខ្ញុំចង់ឱ្យការយល់ខុសទាំងឡាយរលត់បាត់ទៅ។

Besides, I know there is mutual affection between parents and children. Parents have no one to love as their children. For the children, they understand the gratitude owed to their parents. And parents are only persons to love for them. But there are some problems between them. I know about the problems as I have been opening Meditation Centre for children admonishing them. I listen to what they unburden to me. I listen to the feelings of children at the age of Grade (IV), (V), Grade (VI) and up to University level. So, I know their emotion, concerning their parents. Their parents also come to my monastery or ring me up. And they tell me their emotion concerning their children. After discussions with me, tension between them has eased off. But it doesn't last long. Tension increases again as soon as they have arrived back home. I want the misunderstanding to be cleared up.

ដូច្នេះ អ្នកជាមាតាបិតា និងកូនៗត្រូវតែបង្ហាញនូវអារម្មណ៏របស់អ្នកដោយត្រង់ៗ។ និយាយក្នុងនាមជាសមាជិកនៃព្រះសង្ឃ វាជាប្រភេទនៃការផ្សព្វផ្សាយព្រះពុទ្ធសាសនា ព្រោះអ្នកនឹងប្រាប់ពីមាគ៌ាដែលនឹងនាំមកនូវសន្តិភាព និងសេចក្ដីសុខ ដល់មនុស្សទាំង-ឡាយ។ និយាយតាងនាមជំនួសគ្រហស្ថទាំងឡាយ ពាក្យពេចន៏ដែលអ្នកនិយាយទៅ នឹងឆ្លុះបញ្ចាំងនូវអារម្មណ៏របស់មនុស្សទាំង-ឡាយដទៃទៀត។ ដូច្នេះ មាតាបិតាទាំងឡាយចូរបង្ហាញ និង

បញ្ចេញនូវអ្វីដែលអ្នកមានអារម្មណ៍ ហើយព្យាយាមចាប់យកនូវការយល់ដឹងមួយ ។ ហើយនេះនឹងជួយរំដោះនូវភាពតានតឹងរវាងឪពុកម្តាយ និងកូនៗទាំងឡាយនៅទូទាំងពិភពលោកផងដែរ ។ នោះគឺជាកម្មវិធី! នោះ គឺជាគោលបំណងរបស់យើង! តើនរណានឹងចាប់ផ្តើមមុន? លោកអ្នកឪពុកម្តាយ!

So, you, parents and children, do express your feelings frankly. To say as a member of Saṅgha, it is kind of propagating Buddhism because you will be telling ways which will bring peace and happiness to people. To say on behalf of laymen, the words you say will lighten other people's mood. So, parents and children, do express and unburden what you are feeling and try to reach an understanding. And this will help relieve tension between parents and children all over the world. That is the programme! That is our aim! Who will start first? You, parents!

អ្នកស្រី **មូ មូ ឡាង** (Daw Moe Moe Hlaing)

ព្រះតេជគុណដ៏ចម្រើន! យើងកើត និងធំពេញវ័យឡើង នៅក្រោមច្បាប់ដ៏តឹងរ៉ឹងរបស់មាតាបិតាយើង ។ ដូច្នេះ យើងគ្មានសេច-ក្តីសប្បាយគ្រប់គ្រាន់ ដូចមិត្តភក្តិស្រករគ្នារបស់យើងទេ ។ នោះជាហេតុដែលខ្ញុំបណ្តោយកូនៗរបស់ខ្ញុំ ព្រោះខ្ញុំចង់ឱ្យពួកគេសប្បាយរីករាយ និងមិនដូចជាកុមារភាពរបស់ខ្ញុំ ។ ហើយខ្ញុំបានបំពេញបំណងពួកគេគ្រប់បែបយ៉ាង ។ ទោះបីជា ខ្ញុំបណ្តោយពួកគេ តាមដែលខ្ញុំអាចធ្វើបាន ពួកគេនៅតែមិនដឹងគុណឡើយ ។ ពីព្រោះតែការផ្គាប់ផ្គុនរបស់ខ្ញុំគ្មានកំណត់ បំណងប្រាថ្នារបស់ពួកគេក៏រីងរឹតតែគ្មានកំណត់ទៅទៀត ។ ដូច្នេះ ខ្ញុំមានជំនឿថា ពួកគេមានកំណើតកើតជានៅប្រទេសមីយ៉ាន់ម៉ា ឪពុកម្តាយជាពុទ្ធសាសនិក មានតែសាសនាប៉ុណ្ណោះ ដែលអាចដឹកនាំពួកគេឱ្យបានល្អ ។ មានតែពាក្យប្រៀនប្រដៅរបស់សាសនាទេ ដែលអាចធ្វើពួកគេឆ្លាត ហើយអាចឃុំគ្រងខ្លួនពួកគេបាន ។ ដោយសារតែខ្ញុំមិនអាចបញ្ឈប់នូវការផ្គាប់-ផ្គុនរបស់ខ្ញុំសម្រាប់កូនខ្ញុំ ខ្ញុំចង់ដឹងថា តើខ្ញុំអាចធ្វើយ៉ាងដើម្បីគ្រប់-គ្រង និងណែនាំពួកគេទៅ?

Venerable Sir, we had to grow up under the strict rules of our parents. So, we were not happy enough like our peers. That is why, I indulge my children as I want them to be happy and not feel like my childhood. And I have fulfilled all of their desires. Although I indulged them as much as I can, they are not grateful. As there is no limit to my indulgence their desires become unlimited. So, I believe that as they were born of Myanmar, Buddhist parents, only religion can guide them well. Only the teachings of religion would make them smart and able to control themselves. Since I

cannot stop my indulgence for my children, may I know how should I control and guide them?

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda),

ទាក់ទងនឹងបញ្ហានេះ តើមានកូនណាចង់និយាយអ្វីដែរទេ? ។

Concerning the matter, are there any children who want to say something?

អ្នកស្ត្រី **ម៉ា អូមម៉ា អេ** (Daw Ma Ohmma Aye)

ព្រះតេជគុណ! មាតាបិតាតែងទោរទន់ស្រលាញ់កូនរបស់ពួកគេ។ មាតាបិតាគ្រប់រូប គប្បីហ្វឹកហាត់កូនៗរបស់ពួកគេឱ្យទទួលនូវចំណេះដឹង និងជំនាញ។ ខ្ញុំគិតថា ការបណ្តែតបណ្តោយកូនហួសហេតុ អាចឱ្យពួកគេទទួលចំណេះដឹងតិចតួចណាស់។

Venerable Sir, parents tend to love their children. Every parent should train their children to gain knowledge and skill. I suppose, overwhelming indulgence can give them little knowledge.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

ឥឡូវ តើមាននរណាចង់និយាយទេ? តើប៉ែកខាងកូនប្រុសៗវិញ? ។

Well, who want to say? What about from the side of sons?

កញ្ញា **ម៉ា មូ ហ្វីន ព្យូ** (Miss. Ma Moe Pwint Phyu)

ព្រះតេជគុណ! ម្តាយរបស់ខ្ញុំបាននិយាយហើយថា ពួកគេតែងតែបំពេញបំណងតាមដែលខ្ញុំត្រូវការ។ ហើយខ្ញុំក៏សម្តែងអាការៈជាក្មេងស្រីល្អដែរ ប៉ុន្តែ ពេលខ្លះមាតាបិតារបស់ខ្ញុំមិនដែលសរសើរនូវអាកប្បកិរិយាល្អរបស់ខ្ញុំឡើយ។ ត្រូវហើយ កូនស្រីបន្តទៀត។ ពីព្រោះតែពួកគេមិនឱ្យតម្លៃដល់អាកប្បកិរិយាល្អរបស់ខ្ញុំ ជួនកាលខ្ញុំធ្វើចរិតជាក្មេងចចេសរឹងរូស ទោះបីជា ខ្ញុំដឹងពុកម៉ែស្រឡាញ់ខ្ញុំក៏ដោយ។ ជាលទ្ធផល ម៉ែមិនដែលមានមោទនភាព នៅក្នុងលទ្ធផលការសិក្សារបស់ខ្ញុំឡើយ។ ចំណោមអ្នកជិតខាង សាច់ញាតិ មិត្តភក្តិ គាត់មិនដែលទទួលមោទនភាព នៅក្នុងការសិក្សា ឬក៏ការងារសង្គមសោះឡើយ។ ដូច្នេះ ចាប់ពីពេលនេះតទៅ ខ្ញុំសូមប្តូរចិត្តរបស់ខ្ញុំ ធ្វើជាក្មេងល្អឡើងវិញ។

Venerable sir, my mother has said they always fulfilled whatever I need. And I also act as a good girl, but my parents sometimes do not acknowledge my good behaviour. Well, daughter, carry on! As they do not appreciate my good behaviour, I sometimes act as a perverse child although I know my mother loves me. As a result,

mother can never take pride in my educational results. Among neighbours, relatives and friends, she cannot take pride in my educational or social field. So, I have made up my mind to be a good girl from now on.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

នៅពេលមាតាបិតាអប់រំកូនៗរបស់គេ ពួកគេមិនចង់តឹងរ៉ឹងចំពោះកូនពួកគេទេ ប្រសិនបើ មាតាបិតារបស់គេធ្លាប់បានគាបសង្កត់ ដាក់កម្រិតពួកគេ។ ពួកគេមិនចង់វាយកូនគេទេ ប្រសិនបើពុកម៉ែគេធ្លាប់វាយពួកគេ។ ហើយពួកគេស្រឡាញ់កូនពួកគេណាស់ ប្រសិនបើ មាតាបិតារបស់ពួកគេមិនបានផ្តល់នូវសេចក្តីស្រឡាញ់ដល់ពួកគេទេនោះ។ នោះជាធម្មជាតិរបស់មាតាបិតា។ មាតាបិតាមិនចង់ឱ្យកូនរបស់គេ មានបទពិសោធន៍ ដូចដែលពួកគេបានជួបប្រទះឡើយ។ វាជាសេចក្តីស្រឡាញ់របស់មាតាបិតា។

When parents deal with their children, they don't want to restrict their children if they had been restricted by their parents. They don't want to beat their children if they had been beaten. And they want to pamper their children if they had not been pampered by their parents. That is the nature of parents. Parents don't want their children to feel as they did. It is parental love.

ដូច្នេះ ជាដំបូង មាតាបិតាបណ្ដោយកូនរបស់ពួកគេ និងបំពេញគ្រប់តម្រូវការ។ ហើយប៉ែកផ្សេងទៀតនិយាយថា ការបណ្ដោយដោយមិនបានផ្តល់ចំណេះដឹង និងជំនាញ ធ្វើកូនទទម្រើស។ ប្រសិន-បើ ពួកគេចង់ឱ្យកូនរបស់ពួកគេទទួលបាននូវចំណេះដឹង និងជំនាញ មាតាបិតាគួរគប្បីផ្គាប់ផ្គុនកូន។ ហើយមាតាបិតាគប្បីដឹងនូវសមត្ថ-ភាពរបស់កូន។ មាតាបិតាគប្បីអាចវាយតម្លៃថា តើកូនរបស់គេអាចរីកចម្រើនដល់កម្រិត ឬអត់។ មាតាបិតា និងកូនខុសគ្នារវាងអាយុ បទពិសោធន៍ និងចិត្តគំនិត។

So, firstly, parents indulge their children and fulfill everything. And the other sides said that indulgence, without giving knowledge and skills spoils children. If they want their children to gain knowledge and skills, parents should indulge them. And parents should know their children's ability. Parents should be able to evaluate whether their children may be up to their standard or not. Parents and children differ in ages, experiences and thought.

តើមាតាបិតាចង់ឱ្យកូនក្លាយជាអ្វី? តើពួកគេវាយតម្លៃអាក-ប្បកិរិយាល្អរបស់កូនពួកគេដោយរបៀបណា? តាមទស្សនវិស័យព្រះពុទ្ធសាសនា ការថ្វាយបង្គំមាតាបិតា ការនមស្សការព្រឹកល្ងាច

ការដាក់បាត្រព្រះសង្ឃ និងការទទួលសកម្មភាពមរតកសាសនារបស់មាតាបិតា មានន័យថា មានភាពឆ្លាតវៃ។ តើអ្នកចង់ឱ្យកូនរបស់អ្នកឆ្លាតដល់កម្រិតហ្នឹងឬ? តើអ្នកមានបំណងប៉ុណ្ណា? ការផ្គាប់ផ្គុនកូនតែម៉្យាងមិនល្អប្រពៃឡើយ។ ប្រសិនបើ មាតាបិតាចង់ឱ្យកូនរបស់គេដឹកនាំជីវិតប្រកបដោយភាពថ្លៃថ្លា ពួកគេអាចប្រើវិធីច្រើនយ៉ាង។

What do parents want their children to be? How do they evaluate their children's good behaviour? From Buddhism's point of view, paying homage to parents, saying prayer in the morning and evening, offering alms to the monks, and inheriting religious activities of parents mean cleverness. Do you want your child clever that much? How much do you intend? Indulgence only is not good. If parents want their children to lead a prosperous life, they can use more than one way.

មាតាបិតាគប្បីផ្គាប់ផ្គុនកូនតែម៉្យាង ប្រសិនបើ វាធ្វើឱ្យពួកគេឆ្លាត និងសុភាពរាបសា។ ប្រសិនបើ មិនដូច្នោះទេ ពួកគេគប្បីផ្តល់នូវសេចក្តីស្រឡាញ់ថ្នាក់ថ្នម។ ហើយចំពោះកូនវិញ តើអ្នកពិតជាស្រឡាញ់ និងយល់ពីមាតាបិតារបស់អ្នកមែនទេ?។ ចូរព្យាយាមយល់ចិត្តឪពុកម្តាយរបស់អ្នក។ មុនពេលពួកគេបំពេញនូវតម្រូវការរបស់កូន ពួកគេត្រូវតែគិតដោយប្រុងប្រយ័ត្ន។ តើនឹងមានបញ្ហាអ្វីកើតឡើងរវាងភាគីទាំងពីរ ឬសាច់ញាតិ?។ ហើយពួកគេក៏មិនចង់ឱ្យមានការស្តីបន្ទោស ការបែងចែកចំណោមកូននោះដែរ។ ដូច្នេះកូនគប្បីយល់ពីមាតាបិតារបស់គេ ហើយព្យាយាមធ្វើល្អ តាមដែលអាចធ្វើបាន។ កូននៅអាយុស្របាលនេះដឹងច្បាស់ណាស់ថា ពួកគេគួរតែឆ្លាត។

Parents should indulge their children only if it will make them clever and polite. If not, they should be pampered. And as for the children, do you really love and understand your parents? Try to sympathize with your parents. Before they fulfill their children's requirements, they have to think carefully. Will any problem arise between their spouses or relatives? And they also don't want to be accused of differentiating among children. So, children should understand their parents and try to be good as possibly as they can. Children of this age know very well that they should be clever.

ដូច្នេះអ្នកគប្បីធ្វើអាកប្បកិរិយាឱ្យល្អ ឱ្យអស់ពីដួងចិត្តរបស់អ្នក។ ឥឡូវនេះ កូនស្រីនេះទើបតែនិយាយថា ម្តាយឪពុករបស់នាងមិនបានចាត់ទុកគ្រប់គ្រាន់នូវអ្វី ដែលនាងបានព្យាយាមធ្វើឆ្លាតវាងវៃ។ តើអ្នកមានអារម្មណ៍បែបណា ពេលអ្នកដទៃមិនឱ្យតម្លៃ

ទៅលើអំពើល្អរបស់អ្នក? តើអ្នកកើតទុក្ខឬ? ជាការពិត អ្នកនឹងមានអារម្មណ៍សោកស្ដាយ។ វាអាក្រក់ណាស់ នៅពេលអំពើល្អរបស់អ្នកត្រូវគេជេរប្រមាទ អ៊ីចឹងមែនឬ? ឥឡូវទាក់ទងនឹងបញ្ហានេះ ខ្ញុំចង់ប្រាប់ទៅកូនទាំងឡាយ។ កូនស្រីបាននិយាយថា បើទោះបីជា នាងព្យាយាមធ្វើល្អ និងឆ្លាតវៃយ៉ាងណា ក៏ឪពុកម្ដាយរបស់នាងមិនដែលកត់សម្គាល់នាងឡើយ។ ហើយនាងបានចចេសរឹងរូសនឹងមាតាបិតារបស់នាងទៀតផង។

So, you should behave well to your heart's content. Now, this daughter just said that her parents do not regard enough what she has tried to be clever. How do you feel when your goodwill is not valued by others? Are you upset? Of course, you will feel sorry. It is worse when your goodwill is insulted, isn't it? Now concerning this issue, I want to tell the children. The girl said, although she tried to be good and clever, her parents did not recognize her. And she has been perverse to her parents, she said.

តាមពិតទៅ ទោះបីជា គេឱ្យតម្លៃទៅលើអំពើល្អរបស់អ្នក ឬមិនឱ្យ វាមិនមែនជាបញ្ហានោះទេ។ មនុស្សម្នាក់ៗគប្បីឱ្យតម្លៃអំពើល្អខ្លួនឯង។ ជាទូទៅ មនុស្សទាំងឡាយសប្បាយរីករាយណាស់ តែនៅពេលណាដែលគេឱ្យតម្លៃអំពើល្អរបស់ខ្លួន។ ដូច្នេះ យើងត្រូវតែឱ្យតម្លៃអំពើល្អរបស់យើងខ្លួនឯង ទោះបីជា អ្នកដទៃមិនឱ្យតម្លៃក៏ដោយ។ តើអ្នកយល់ពីអ្វីដែលខ្ញុំបាននិយាយទេ?។ ម្ដាយ ឬឪពុករបស់អ្នក អាចពូកែលើស ឬថា ពួកគេមិនអាចដឹងច្រើនដូចរូបអ្នកនោះទេ។ ដូច្នេះ ខ្ញុំចង់និយាយថា ប្រសិនបើពុកម៉ែរបស់អ្នកមិនឱ្យតម្លៃអំពើល្អរបស់អ្នកទេ ទុកឱ្យវាអាសាបង់ចុះ!។ ប្រសិនបើអ្នកឱ្យតម្លៃវាដោយខ្លួនអ្នក ចូរឱ្យតម្លៃវានៅពេល ដែលម្ដាយឪពុកអ្នកនៅមានជីវិត និងឱ្យតម្លៃវានៅពេលពួកគាត់ផុតជីវិតផងដែរ។ តើអ្នកអាចធ្វើដូច្នេះបាន ឬមិនបាន?។ អ្នកដឹង ថាតើធ្វើយ៉ាងណាទើបជាមនុស្សឆ្លាត និងសុភាពរាបសា?។ ចូរឱ្យតម្លៃសីលធម៌ និងអំពើល្អរបស់អ្នក។ តេជគុណ សូមរំលឹកអ្នកទាំងអស់គ្នានូវចំណុចនេះ។

In fact, whether your goodwill is valued or not, it does not matter. Everybody should value his own goodwill. Generally, people are pleased only when their benevolence is treasured. So, we must value our goodwill by ourselves… whether it is valued by other people or not. Do you understand what I have said? Your mum or dad may excel you or they may not know as much as you do. So, I want to say that if your parents do not appreciate your goodwill, let it be! If you value it by yourself, value it when your parents are still alive and value it when they are done too. Can you do that or can you not? You know how to

be clever and polite. Do treasure your morale and goodwill. Phonphon has called you up here.

## **ជំពូក ២**

Part II:

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

ហេតុអ្វីបានជាក្រុមនីមួយៗ ឬកូនចៅកម្រមានឱកាសនិយាយឡើង អ៊ីចឹងហ្ន៎? មាតាបិតាមានអារម្មណ៍ផ្ទាល់ខ្លួនពួកគេចំពោះកូនរបស់ខ្លួន។ នៅខាងផ្នែករបស់ពួកគេ កូនទាំងឡាយត្រូវតែសង្កត់នូវពាក្យសម្ដី ដូច្នេះ នឹងមិនមានការវាយបកពាក្យសម្ដីមកវិញទេ។ ឥឡូវ អ្នកទាំងអស់គ្នា ចូរនិយាយវាឡើង!។

Why? Each group or offspring, rarely has the chance to speak up. Parents have their own feelings concerning their children. Children, on their part, often have to suppress their speech so as not to seem to be retorting back. Now all of you, out with it!

**ធម្មទូត** គឺជាអ្នកទ្រទ្រង់ ឬថា ជាបេសកជននៃពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ។ មាតាបិតា និងកូនៗទាំងឡាយបានអញ្ជើញមកសួរសុខទុក្ខខ្ញុំដាច់ដោយឡែកពីគ្នា។ គ្រប់ពេលខ្ញុំបានដោះស្រាយបញ្ហាឱ្យពួកគេ និងអារម្មណ៍តានតឹងរបស់គេ។ ការនិយាយពីបញ្ហាទាំងឡាយជាបុគ្គល ដោយសមាជិកនៃគ្រួសារមួយមិនគ្រប់គ្រាន់នោះទេ។ ការពិភាក្សាដោយបើកចំហ រវាងក្រុមទាំងពីរបានធ្វើឱ្យដឹងជាសាកល អាចផ្សព្វផ្សាយនូវសន្តិភាពយ៉ាងច្រើនទៅក្នុងជីវិតគ្រួសារ។ តើមាតាបិតាមានអារម្មណ៍មិនអស់ចិត្ត ដូចកូនរបស់ពួកគេទេ?។ ត្រូវហើយ ពួកគេដូចគ្នា។ តើកូនទាំងឡាយសង្ឃឹមលើពុកម៉ែកាន់តែខ្លាំងដែរទេ?។ ត្រូវហើយ ពួកគេត្រូវការ! អ៊ីចឹង សូមលើកឡើងមក!។ ឥឡូវនេះ តើប៉ែកខាងណានឹងចាប់ផ្ដើមមុន?។

A Dhammaduta is bearer, or envoy of the teachings of the Buddha. Parents and children have visited me separately. Then and there I have resolved their problems, their suppressed feelings. Addressing the problems individually by members of a family is not enough. Discussion in an open manner between the two groups, made known internationally, would contribute much to peace in the life of the family. Do parents feel unsatisfactoriness as to their children? Yes, they do. Do children expect more of their parents? Yes, they do; so, out with it! Now which side will start first?

កញ្ញា ម៉ា ខាញ សា លីន (Daw Ma Khine Zar Linn)

យើងដឹងគុណនៃសេចក្តីស្រឡាញ់ ដែលមាតាបិតាមានសម្រាប់ពួកយើង។ ប៉ុន្តែ មាតាបិតាមួយចំនួន មានការប្រកាន់ខ្លួនបន្តិច ឬក៏ហាក់បីដូចជាប្រកាន់ឫក ក្នុងការស្រឡាញ់កូនរបស់ពួកគេ។ ពួកគេគប្បីមានចំណេះដឹងជ្រៅជ្រះ។ ភាពជាមាតាបិតាចាប់ផ្តើមតាំងពីមានគភ៌មកម្ល៉េះ។ កត្តាសំខាន់មួយទៀត គឺភាពមិនលំអៀងខាងផ្នែកមាតាបិតា ដែលជាការពិតមិនមានទាក់ទងជាមួយមាតាបិតាមានកូនតែមួយទេ។ ជារឿយៗ មាតាបិតាទោរទន់ស្រឡាញ់កូនស្ងួនមួយ ច្រើនជាងបងប្អូនដទៃទៀត។ កូនដទៃទាំងនោះមានអារម្មណ៍ ជាការបែងចែក តែមិននិយាយស្តី។ តើបញ្ហានេះធ្វើយ៉ាងណាទើបអាចដឹងបាន, ព្រះតេជគុណ? ។

We recognize the incomparable love parents have for us. Still, some parents have a bit much of "Atta", or the seeming entity of self, in loving their children. They ought to have sharp knowledge. Parenthood starts with a pregnancy. Another crucial factor is fairness on parents' part, which is, of course, irrelevant to parents with a single child. Often parents tend to love a child more than other siblings. Those other children feel the differentiation but not speak it up. How can this be made known, Venerable?

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

មាតាបិតា តើអ្នកគួរឆ្លើយតបរបៀបណា? ។
How would you reply, parents?

អ្នកស្រី **ឃីន ថាន តាយ** (Daw Khin Than Htay)

អ្វីដែលកូនស្រីទើបនិយាយមិញ គឺត្រឹមត្រូវហើយ។ យើងមានទំនួលខុសត្រូវចំពោះពួកគេ តាំងពីនៅជាគភ៌។ ខ្ញុំមានបីលើក ប៉ុន្តែខ្ញុំនៅសល់តែកូនប្រុសមួយប៉ុណ្ណោះ។ សូម្បីតែនៅកំឡុងមានគភ៌ម្តងៗ ខ្ញុំបានធ្វើសក្ការៈបូជាយ៉ាងខ្លាំងបំផុតដល់ព្រះត្រៃសរណគមន៍ ដោយបន់ស្រន់សូមឱ្យប្រសូតកូនល្អប្រកបដោគជ័យ។ ខ្ញុំមានអារម្មណ៍ល្អបំផុតចំពោះកូន។ ក្រោយមក ខ្ញុំជាម្តាយចិញ្ចឹមក្មួយប្រុសពីរបីនាក់ទៀត ចាប់តាំងពីម្តាយរបស់ពួកគេស្លាប់ទៅ។ ខ្ញុំមិនដែលបែងចែករវាងកូនប្រុស និងកូនចិញ្ចឹមឡើយ។ ដូច្នេះ ការអះអាងដែលឪពុកម្តាយគ្រប់រូបលំអៀងបែងចែករវាងគាត់ ឬនាងមិនអាចត្រឹមត្រូវទេ តើកូនៗស្រឡាញ់មាតាបិតាពិតឬ? ទោះបីជាយ៉ាងណាខ្ញុំមានជំនឿ បន្ទាប់ពីស្តាប់ធម្មទេសនារបស់ព្រះតេជគុណនៅនឹងស៊ីឌីនិងវីឌីអូកាសែត ដែលថា កូននឹងស្រឡាញ់តបមកមាតាបិតាដ៏ជាទីស្រឡាញ់វិញអស់ពីដួងចិត្ត។

What the Thamee (daughter) just said is correct. We are responsible to them since pregnancy. I have had it thrice, but am left with

only one son. Even during each pregnancy I most seriously adored The Three Gems, praying for a successful birth of a would-be good child. I harboured good intentions to the fullest. Then, I have been foster mother to my nephew, whose mother had since died. I have never differentiated between son and foster-son. So, the claims that every parent tends to differentiate between his/her children cannot be true-again, do children love their parents, really? However, I would like to believe, after listening to your sermons contained in audio-and video-cassette, that children will love back to loving parents to the fullest.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

តើមានទៀតទេប៉ែកខាងមាតាបិតា? តើនរណានឹងនិយាយពីការបែងចែកសេចក្តីស្រឡាញ់កូន?

Any more on parents' part? Who will speak on differentiation in love of children?

លោក **វីន អូ** (U Win Oo):

ខ្ញុំមានកូនស្រីពីរនាក់។ ដោយសារតែអត្តៈរបស់ខ្ញុំ ខ្ញុំបានវាយកូន១ ចំណោមអ្នកទាំងពីរ។ ពេលមួយខ្ញុំបានវាយនាងយ៉ាងធ្ងន់ដល់ថ្នាក់នាងដួល។ ខ្ញុំបានដឹងថា នាងឈឺចុកចាប់ក្នុងដួងចិត្ត។ នៅយប់នោះ ខ្លួនខ្ញុំផ្ទាល់ក៏ដេកមិនលក់ដែរ ប៉ុន្តែ នៅពេលជួបនាង ខ្ញុំបានរក្សាទឹកមុខធម្មតា។ តើនាងឆ្លើយតបយ៉ាងណា? នៅយប់មួយពេលសុំឱ្យនាងលេងប្យាណូ ដែលនាងលេងយ៉ាងល្អ ការគុំកូនរបស់នាងបានស្តែងចេញឱ្យឃើញដោយខ្លួនវា។ នាងលេងយ៉ាងអន់បំផុតដែលធ្វើឱ្យខ្ញុំដើរចេញពីបន្ទប់។ បន្ទាប់ពីយប់នោះ នាងបានសុំទោសខ្ញុំ។ នេះគឺមកពីការច្បាំងនៃឆន្ទៈ។

I have two daughters. Suppressing my Atta, I struck one of them. Once I struck her so hard that she fell down. I knew she would be pained at heart. I myself did not sleep well that night, but, when facing her, I kept a stern face. How did she respond? When I asked one night to play the organ for me, which she plays well, her grudge revealed itself. She played so badly that I left the room. Later that night she apologizes to me. This is a contest of wills!

ដូច្នេះ មាតាបិតាគប្បីប្រើភាពឆ្លាតវៃ ក្នុងការព្យាយាមបង្រៀនកូនពីអំពើល្អ។ ចំណុចមួយទៀត បញ្ហានេះសាមញ្ញទេ ចំពោះឪពុកម្តាយទាំងឡាយដែលមានកូនពីរ ឬលើសពីនេះ។ កូនម្នាក់ ឬកូនច្រើនទៀត អាចមើលឃើញនូវសកម្មភាពរបស់មាតាបិតា ដែលជាអ្វីហៅថា លំអៀងនោះ។ រឿងនេះវាកើតឡើងច្បាស់ណាស់ចំពោះ

រូបខ្ញុំផ្ទាល់។ ខ្ញុំបានបញ្ជូនកូនស្រីច្បងរបស់ខ្ញុំទៅ មុនញ៉ូវ (Monywa) រៀនកុំព្យូទ័រដែលត្រូវចំណាយលុយច្រើន បន្ទាប់ពីបញ្ចប់មធ្យមសិក្សា។ ដោយដឹងពីរឿងនេះ កូនស្រីពៅថ្នាក់ទី១០ ក៏បានទាមទារឱ្យខ្ញុំបញ្ជូននាង ទៅមណ្ឌលប្រលងដែលល្អប្រសើរជាងនៅភូមិរបស់យើង។ ដូច្នេះ ខ្ញុំត្រូវតែបញ្ជូននាងទៅកាន់សាលាចំណេះដឹងទូទៅមួយ នៅសាហ្គាំង (Sagaing)។ ប្រសិនបើ ខ្ញុំមិនយល់ព្រមតាមសេចក្ដីប្រាថ្នារបស់នាងទេ នាងប្រាកដមានជំនឿពីខ្វះសេចក្ដីស្រឡាញ់ចំពោះនាង ប៉ែកខាងខ្ញុំ។ ប៉ុន្តែ មាតាបិតាត្រូវតែយកចិត្តទុកដាក់ហេរញ្ញវត្ថុគ្រួសារ។ ក្នុងការផ្ដល់នូវការអប់រំសីលធមិដល់កូន យើងជាមាតាបិតាត្រូវមានចំណេះដឹង និងជំនាញផងដែរ។ មាតាបិតាជាច្រើនដាក់វិន័យតឹងរ៉ឹងពីយុវជន ចង់ឱ្យកូនរបស់ពួកគេរស់នៅដូចខ្លួនគាត់ពីដើម។ តាមការពិត ពួកគេស្រឡាញ់កូនរបស់គេ ប៉ុន្តែពួកគេបានបាត់បង់ នៅពេលមានជម្លោះជាមួយនឹងអត្តៈផ្ទាល់របស់ពួកគេ។

So, parents should use cleverness in trying to teach children good conduct. Another point, this would be common to parents with two or more children. A certain child (or certain children) might view their parents' action somewhat biased. This has been personally true to me. My elder daughter, after matriculation, was sent to Monywa for computer training at much expense. Knowing this, 10-grade younger daughter demanded of me to send her to a "better" exam centre other than our own village. Thus she had to be sent to a boarding school in Sagaing. If I had not complied with her wish, she would surely have believed in lack of love towards her on my part. But parents have to take care of family finances. In giving moral training to children, we parents need to have knowledge and skills. Many parents, strict disciplinarians from youth, would like their children living like their former selves. Thus they begin pampering their children, but lose out when in conflict with their own 'Atta'.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda):

តើមាតាបិតាចង់និយាយអ្វីទេ? ។
What would parents like to say?

លោក **ម៉ាឃ្ល ណាំង លីន ធេង** (U Mg Naing Linn Thein)

ព្រះតេជគុណជាទីគោរព, មាតាបិតាស្រឡាញ់បុត្រធីតា។ វានឹងមិនមានគ្រួសារណា មានសុភមង្គលឡើយ ប្រសិនបើ ពួកគេមានទស្សនវិស័យពីរផ្សេងគ្នានោះ។ បញ្ហាទាំងឡាយក៏នឹងមិនមានទៀតដែរ ប្រសិនបើ មាតាបិតាទាំងឡាយយល់ និងទទួលកូនរបស់

ពួកគេ និងការអភ័យ ។ ឪពុកម្ដាយ គឺជាគំរូ ដែលជាអ្នកមានឥទ្ធិពលយ៉ាងងាយ ទៅលើបុត្រទាំងឡាយ ។ ខ្ញុំគិតថា កូនមិនមានកំហុសនោះទេ ហើយពួកគេអាចប្រែប្រួលទៅតាមបរិស្ថានខាងក្រៅ ជាពិសេសកម្មភាព និងបែបបទជីវិតរស់នៅរបស់មាតាបិតា របស់ពួកគេ ។ ទស្សនវិស័យពីរផ្ទុយគ្នា ក៏នឹងមិនកើតមានទៀតឡើយ បើឪពុកម្ដាយមានបរិបូរដោយសេចក្ដីយល់ដឹង ។ តាមការពិតទៅ គ្មានហេតុផលណាបណ្ដាលឱ្យមានបដិវាទកម្ម ចំពោះអត្តទត្ថភាពរវាងមាតាបិតា និងកូនទេ ។

Your Venerable, parents love children. There will be no home sweet home if they have two differing perspectives! There will be no more problems if the parents understand and accept their children and vice versa. The parents are the models who can easily influence their children. I think the children are innocent and they can adapt the environment, especially their parents' mode and life-style. There will be no more differing perspectives if both the parents and children have full of understanding. Actually, there is no reason to cause contradiction for the selfishness between parents and children.

ខ្ញុំគិតថា ការអានព្រះពុទ្ធវចនៈ និងសៀវភៅឱ្យបានច្រើន គឺជាមាគ៌ាមួយធ្វើឱ្យរីកធំឡើងនូវព្រំដែននៃចំណេះដឹង ។ តាមធីរិនេះ បញ្ហាទាំងឡាយនឹងត្រូវបានថយចុះ ។ ខ្ញុំយល់ថា ការពិន័យខ្លាំងក្លាដូចជា ការវាយដំកូនគួរគប្បីចៀសវាងឱ្យផុត ។ ព្រោះពួកគេក្មេងខ្ចីណាស់ ពួកគេនឹងរងការឈឺចាប់ទាំងផ្នែកផ្លូវកាយ និងផ្លូវចិត្តបណ្ដាលឱ្យមានការអំពល់ចិត្តប្រឆាំងនឹងសង្គមទៀតផង ។

I wish that reading more Buddhist teachings and books is the way to widen the scope of knowledge. In this way, the problems will be reduced. I wish that harsh punishment like beating to the child should be avoided. As they are too fragile, they will get hurt physically and mentally causing fixation of anti-social feelings.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

កូនស្រីនោះបាននិយាយថា មាតាបិតាទាំងឡាយមានអត្តៈធំ ។ ពួកគេនិយាយថា មាតាបិតាដែលមានកូនចាប់ពី ៣, ៤, ៥ នាក់ឡើងទៅតែងមានលំអៀង ។ នោះគឺត្រឹមត្រូវ ។ តើមូលហេតុអ្វី? ពុកម៉ែចង់ឱ្យកូនចៅរបស់ពួកគេឆ្លាត និងមានគុណធម៌លើសពីពួកគេទៅទៀត ។ តាមពិត មាតាបិតាស្រឡាញ់បុត្រ ប៉ុន្តែពួកគេចង់តម្រង់កូនទៅតាមផ្គត់នៃការពេញចិត្តពួកគេ ។ ការតម្រង់ទិសនេះពួកគេមិនអាចធ្វើកើតទេ ។ ពុកម៉ែតែងតែគិតថា យើងជាវេជ្ជ--បណ្ឌិត ហើយកូនរបស់យើងគួរគប្បីជាវេជ្ជបណ្ឌិតដែរ ។ ឬថា យើង

មិនបានសម្រេចបំណងជាវេជ្ជបណ្ឌិតទេ ប៉ុន្តែកូនរបស់យើងគួរគប្បីសម្រេចបាន។ ដូចគ្នានេះដែរ ប្រសិនបើ ពួកយើងមិនបានក្លាយជាវិស្វករទេ កូនរបស់យើងត្រូវតែក្លាយជាវិស្វករ។ នោះហើយជាវិធីដែលយើងតែងរិះគិត។

That daughter said, parents have big atta. They say parents with 3-4-5 children tend to be biased. That is true! Why? Parents want their offspring surpassing them, cleverer and more cultured. They love the children, of course, but want to shape them in the mould of their liking. But wax they are not. Parents tend to think: We are doctors, and our children should be doctors too. Or, we have not managed to achieve a career as doctor, but our children should achieve it. Just as similarly, even if we have not become engineers, our children must. That is how we tend to think.

លើសពីនេះទៅទៀត ម្តាយឪពុកស្ទើរតែទាំងអស់ចូរចិត្តរិះគិតចាត់ទុកកូនរបស់ពួកគេ ដូចជាតុក្កតាជ័រផលិតនៅក្នុងពុម្ពដូច្នោះ។ ពួកគេមិនបានខ្វល់អំពីបទពិសោធន៏ ឬក៏ស្មារតីរបស់កូនបន្តិចសោះ។ តាមមាគ៌ានេះ អារម្មណ៏អាថិកំបាំងជាច្រើនទៀតនៅសល់ជាប់ជាមួយកូនរបស់ពួកគេ។ នេះជាការពន្យល់ពីអត្តៈធំនៃពុកម៉ែ។ តើពុកម៉ែចង់ឱ្យកូនក្លាយជាអ្វី?។ ចូរបណ្តោយតាមការបត់បែនរបស់កូន ជំនាញរបស់គាត់ អាស្រ័យលើសមត្ថភាពរបស់គាត់ ដឹងដោយខ្លួនគាត់ គឺជាមាគ៌ាល្អបំផុត។ ឪពុកម្តាយមិនគួររុញច្រានពួកគេទេ ប៉ុន្តែ ឪពុកម្តាយគ្រាន់តែចាំមើលខ្លាចក្រែងពួកគេដួលនៅលើផ្លូវបានហើយ។

Moreover, most parents would like to consider their children just plastic toys produced in a mould. They would not care a tiny bit about their children's experience or mentality. In this way, many latent feelings remain with their children. This is explaining the big Atta of parents'. What would you parents like them to become? Giving rein to a child's bent, his skill, depending on his ability perceived by himself, is the best way. Parents should not push them; they should just see to it that their children do not fall on the way.

ម៉្យាងវិញទៀត មាតាបិតាមិនគួរលុតដំកូនហួសហេតុពេកនោះឡើយ គ្រាន់តែយកចិត្តទុកដាក់ថែរក្សា កុំឱ្យពួកគេមានការឈឺចាប់។ ការពត់ពួកគេតាមតែអ្នកចូលចិត្ត វាធ្ងន់ធ្ងរពេកហើយ។ មាតាបិតាទាំងឡាយ! ចូរញ៉ាំងអត្តៈរបស់អ្នកឱ្យអន់ថយទៅណា។ កូនខ្លះទំនងជាខ្សោយខាងផ្នែកស្មារតី។ លុតដំកូនបែបនេះ ការវាស់វែងតាមតែខ្លួនអ្នក អាចនាំឱ្យកូនក្លាយជាវិកលចរិត ឬក្លាយជាឈឺចាប់ក្នុងចិត្ត។ ពួកគេអាចចងកំហឹងចំពោះអ្នកទៀតផង។ តាមធាតុ

ពិត កូនមិនដែលស្អប់ពុកម៉ែទេ។ ប្រសិនបើ ពួកគេចាប់ផ្តើមស្អប់អ្នក វាជាកំហុសរបស់អ្នក ដែលវិលទៅរកអត្តទត្ថភាពរបស់អ្នកនោះឯង។

In other words, they should not drive them too much, only taking care that they remain unharmed. To mould as you like it-- it is an extreme, Parents! Have your <u>*atta*</u> lessened. Some children might be deficient in intelligence. To drive such ones enough, to measure up to you, means they could go crazy, or become pained at heart. They could even develop hatred towards you. Originally, children do not hate their parents. If they start hating you, it's your fault, which in turn is your <u>*atta*</u>.

បន្ទាប់មក កូនស្រីបានអះអាងថា មាតាបិតាស្រឡាញ់រាប់អានកូនចៅមួយចំនួន ជាងកូនចៅផ្សេងទៀត។ ពួកគេប្រហែលជាអ៊ីចឹងមែន ប៉ុន្តែ មានហេតុផលច្រើនណាស់។ នៅក្នុងគ្រួសារមួយ ពេល-វេលានៃភាពរុងរឿងរួមគ្នាដោយផ្តល់កំណើតដល់កូន ហើយពួកគេស្រឡាញ់ពួកគេខ្លាំងណាស់។ ករណីផ្ទុយពីនេះ កូនណាកើតក្នុងពេលលំបាកត្រូវគេគិតថា អត់សំណាង។ ជាក់ស្តែង ការបែងចែកចំ-ណោមកូនចៅផ្ទាល់របស់ខ្លួន អាចនាំឱ្យមានការបែកបាក់គ្រួសារ។

Then, that daughter has claimed parents treat some offspring more favourable than others. Perhaps they do; but there are a lot of reasons. In a family, times of prosperity coincide with the birth of certain children, and they are pampered a lot. In the opposite case, those born in hard times are considered a source of misfortune. In truth, differentiation among one's own offspring could lead to disintegration of the family.

ចំពោះរឿងដ៏អាក្រក់បំផុត នៅក្នុងវប្បធម៌ប្រពៃណីរបស់យើង មាតាបិតាកើតថ្ងៃអង្គារ គឺភ័យបំផុតមានកូនចៅកើតថ្ងៃអាទិត្យ ដោយស្មានជាសត្រូវរបស់គាត់។ មាតានោះត្រូវចៀសវាងការងារនៅថ្ងៃអាទិត្យ។ នោះគឺខ្វះមេត្តា សេចក្តីស្រឡាញ់សន្តោសប៉ែកខាងមាតា។ មនុស្សណាក៏ដោយ គឺកើតមកដោយសារតែកម្មអតីតរបស់គាត់ ឬនាង ឬបារមីនៅក្នុងភពមុន។ មាតាបិតា! នរណាដែលកើតជាមួយអ្នក គឺជាកូនចៅរបស់អ្នក វាជាកាតព្វកិច្ចរបស់អ្នកក្នុងការស្រឡាញ់កូនចៅរបស់អ្នក។ ប្រសិនបើ អ្នកចាប់ផ្តើមស្អប់កូនចៅកើតនៅសប្តាហ៍នោះ អ៊ីចឹង លទ្ធភាពសេចក្តីស្រឡាញ់របស់អ្នកបានអន់ចុះ គួរឱ្យសោកស្តាយ។

For the worst, in our traditional culture, a Tuesday-born parent is in great fear to have a Sunday-day offspring, who is supposedly his enemy. That mother goes to great lengths to avoid

labour on a Sunday. That is lack of *mettā,* or loving-kindness, on her part. Any human being is reborn on account of his/her past actions or perfection in the previous existence. Parents, whoever is born of you are your offspring; it is your duty to love your offspring. If you start hating the offspring born on a certain weekday, then your capacity for love has diminished miserably.

ប្រសិនបើ អ្នកខ្វល់ចំពោះតែសេចក្ដីប្រាថ្នារបស់អ្នក ដោយចាប់ផ្ដើមថ្ងៃ ការងារទៅតាមជម្រើសរបស់អ្នក តើបញ្ហានេះប្រព្រឹត្តទៅតាមធម្មជាតិយ៉ាងណា នៅផ្នែកទារកក្នុងផ្ទៃរបស់អ្នក? ។ គាត់កើតមកច្បាស់ជាឈឺចាប់ផ្លូវចិត្តហើយ ។ តាមពិត សេចក្ដីរីករាយ ពិតជាមានប្រាកដ ។ អ្នកអាចស្រឡាញ់តាមតែអ្នកចូលចិត្ត ប៉ុន្តែចូរពិចារណាគ្រប់ផ្នែក ។ ឧបមាថា អ្នកមានកូនស្រីពីរនាក់ ឬកូនប្រុសពីរនាក់ ។ តើអាចសម្រេចចិត្តបញ្ជូនកូនចៅតែម្នាក់ទៅរៀនសាលាល្អ ចំណែកឯម្នាក់ទៀតមិនបញ្ជូនទៅរបៀបណា? ។ ដើម្បីបង្ហាញពីមេត្តាចិត្តជាមាតាបិតាពិតប្រាកដ ដាច់ខាតអ្នកត្រូវតែនៅស្មើ ។ អ្នកត្រូវតែស្រឡាញ់កូនទាំងអស់របស់អ្នក មិនត្រូវពេញចិត្តខ្លះ ច្រើនជាងខ្លះទៀតនោះឡើយ ។ ប៉ុន្តែ ឥទ្ធិពលអាក្រក់មួយបានកើតចេញឡើង ។ មាតាបិតាមួយចំនួនចង់ឱ្យកូនកើតតាមការនិយាយរបស់ហោរាសាស្ត្រ នៅក្រោមដួងរាសី និងភពដ៏ល្អ ហើយស្រឡាញ់កូនដែលកើតនៅពេលចម្រើនរុងរឿង មិនស្រឡាញ់កូនដែលកើតនៅភាពលំបាកឡើយ ។ នេះជារឿងអបិយជំនឿ ពោលគឺជារឿងខុស ។ កូនចៅ គឺនៅតែជាកូនចៅអ៊ីចឹង ទោះបីជាគាត់ ឬនាងកើតថ្ងៃណាសប្ដាហ៍ណាក៏ដោយ ។ អបិយជំនឿរបស់អ្នកនេះ នឹងនាំឱ្យមកនូវបក្ខានុគ្រោះប៉ុណ្ណោះ ។ គ្មានអ្វីទៀតឡើយ ។

If you care for your wish only, starting with the day of labour of your choice, how could it run a natural course on the part of the baby in your womb? He would be born already pained at heart. Of course, acting in favour does exist. You may love as you feel like it, but consider every side. Suppose you have two daughters, or two sons. How could you decide to send only one offspring to a good school while leaving the other? To harbor true parental loving-kindness, you have to be absolutely fair. You have to love your children all, without favouring some more than others. But a bad influence has appeared. Some parents want their children to be born, astrologically speaking, under the right stars and planet, and love the children born in prosperous times and not those born in times of hardship. This is being superstitious—and wrong! And offspring is an offspring on whatever weekday he/she is born. Your superstition will only lead to favouritism. That is all.

## ផ្នែកទី ៣ (A)

## Part III: (A)

សង្គហធម៌ ៥ ប្រការរបស់បុត្រធីតា គឺៈ-

ក. ត្រូវទំនុកបម្រុងចិញ្ចឹមមាតាបិតា,

ខ. ត្រូវធ្វើការងារជំនួសមាតាបិតា,

គ. ត្រូវទំនុកបម្រុងវង្សត្រកូលមិនឱ្យសាបសូន្យ,

ឃ. ត្រូវប្រតិបត្តិសមគួរជាអ្នកទទួលមតិក,

ង. ត្រូវធ្វើបុណ្យឧទ្ទិសកុសល ពេលលោកស្លាប់ទៅ។

Five kinds of Duty for Sons and Daughters are:

a- They support the parents in turn;
b- Manage affairs on their behalf;
c- Maintain the honour and tranditions of the family;
d- Make hemselves worthy of inheritance by obeying the parents;
e- Offer alms on behalf of the departed parents.

អ្នកស្រី **ង្វេ ឡា** (Daw Ngwe Hla)

ខ្ញុំករុណាសូមប្រាប់ព្រះតេជគុណ។ មាតាទាំងឡាយទទួលបន្ទុកខាងកិច្ចការផ្ទះស្ទើរតែទាំងអស់ ប៉ុន្តែ កូនខ្លះទោរទន់គោរពស្រឡាញ់បិតាច្រើនជាង។ ជាទូទៅ គាត់ជាអ្នករកចំណូល។ ប៉ុន្តែវាផ្ទុយពិតមែនហើយ ក្នុងករណី មាតាដែលជាអ្នកមេគ្រួសារ។ នៅពេល មាតាជាអ្នករកចំណូលធំជាងបិតា កូនគោរពនាងច្រើន។ ដូច្នេះ អ្នកទាំងអស់គ្នាឃើញហើយ កូនខ្លះក៏ប្រកាន់ផងដែរ។

May I address you, Venerable Sir. Mothers are mostly responsible for the chores at home, but some children tend to pay more regard to the father. Generally he is the bread-earner. But, the reverse is true in case of the mother who leads in household affairs. When the mother instead of the father brings the main income, she is given more regard. So, you see, some children also are discriminate.

អ្នកស្រី **ម៉ា ឆឺរី អោង** (Daw Ma Cherry Aung)

អ្វីដែលនាងទើបតែនិយាយមិញ ព្រោះតែសេចក្តីយល់ខុស។ បិតា មិនបាននាំមកសេចក្តីរីករាយច្រើនជាងទេ ប៉ុន្តែគ្រាន់តែមានភាពកកក្តៅច្រើនជាង ពេលគាត់វិលត្រឡប់មកពីការធ្វើការងារវិញ។ ដូច្នេះវាហាក់បីដូចជា គាត់ទទួលសេចក្តីពេញចិត្តចំពោះតែអំណាចរកចំណូលរបស់គាត់ប៉ុណ្ណោះ។ រឿងនេះមិនត្រូវទាល់តែសោះ។

What she just said is due to misunderstanding. Father wasn't getting more favour, but getting more care on returning home from official trips. Thus is seemed he was received favours for his earning power. It is not true at all.

អ្នកស្រីបណ្ឌិត **ឃីន សាន នេ្វ** (Dr. Daw Khin San Nwe)

សូមអនុញ្ញាតឱ្យខ្ញុំបន្ថែមនូវបញ្ហាខ្លះៗ។ ខ្ញុំជាអ្នកទទួលខុសត្រូវផ្នែកកិច្ចការស្ត្រី និងកុមារ នៅសហព័ន្ធកិច្ចការស្ត្រីមីយ៉ាន់ម៉ា និងនៅក្នុងកិច្ចការអភិវឌ្ឍន៍ស្ត្រីផងដែរ។ ទោះជាយ៉ាងណា មាតាគឺជាមនុស្សសំខាន់បំផុតមួយរូបនៅក្នុងគ្រួសារ ឬក៏មេផ្ទះ។ ដូចកូនៗបានពន្យល់មកហើយ ពោលគឺ មិនចាំបាច់មានការប្រកួតប្រជែងរវាងមាតាទាំងឡាយ និងកូនៗទេ។ ខ្ញុំមានកូនប្រុសតែមួយគត់។ មានចំណងខ្លាំងណាស់រវាងយើង សម្រាប់ខ្លួនខ្ញុំ ខ្ញុំតែងតែគិតពីកូនចៅ ទុកដូចជាកែវភ្នែកអ៊ីចឹង។ យើងស្រឡាញ់គ្នាទៅវិញទៅមក ដែលគាត់តែងតែគោរពខ្ញុំ។ ខ្ញុំផ្តល់ឱកាសឱ្យគាត់ស្រឡាញ់ខ្ញុំគ្រប់ពេលវេលា។

Let me add something. I am concerned with women's and children's affair at MWAF (Myanmar Women's Affair Federation), and also into women's development work. Whatever, a mother is the most important in a family or household. As the children explained—there is no need for rivalry between mothers and children. I have a child only--a son. There is a deep attachment between us, for I always consider an offspring my looking-glass. We are so beloved of one another that he always obeys me. I give him every chance to love me.

យើងមានត្រឹមតែមេត្តាធម៌សម្រាប់កូនចៅ កូនប្រុស និងកូនស្រីទាំងអស់ប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំគិតថា មិនមានភាពលំបាករវាងមាតាបិតា និងកូនចៅឡើយ។ ពួកគេមាននិន្នាការមួយតាមធម្មជាតិដើម្បីទៅមនុស្សល្អ។ ប៉ុន្តែ ពួកគេហាក់បីដូចជា អ្នកពិសោធ ពោលគឺ ចង់ដឹងនូវអ្វីដែលល្អ និងអ្វីដែលអាក្រក់។ សូម្បីតែពួកគេព្យាយាមជក់។ ចំពោះរឿងនេះ យើងគប្បីទូន្មានពួកគេជាការប្រសើរ។ កូនប្រុសអាចនឹងមានជម្ងឺក្អក ឬកើតជម្ងឺ។ បន្ទាប់មក យើងអាចប្រាប់គាត់ "កូនប្រុស! នេះហើយជាផលនៃការជក់។ ចូរវៀរចាកការជក់ទៅណា"។ ហើយយើងគប្បីពន្យល់ឱ្យច្បាស់អំពីគ្រោះថ្នាក់ដើម្បីឱ្យពួកគេអាចវៀរចាកការជក់បាន។ ម្តាយគប្បីនៅឃ្លាំមើលនូវអាកប្បកិរិយារបស់កូនចៅ ចូរបង្កើននូវចំណងរវាងពួកគេ ហើយទូន្មានពួកគេ ជាមួយនឹងប្រាជ្ញាដ៏មុតស្រួច ប្រឆាំងនឹងអាកប្បកិរិយាកូនរបស់ពួកគេ។

We have only loving-kindness for offspring and sons and daughters return it. So, no difficulty between parents and offspring, I should think. They have an innate tendency to be well-behaved. But they are likely to experiment--to know what is good, or bad. They even try smoking. For this we better counsel them. The son would be coughing, or ill. Then, we can tell, “That is it, son. Refrain from smoking”. And we might explain well to them about the dangers so that they would refrain from smoking. A mother should always watch out for an offspring’s behaviour, cultivate attachment between themselves, and counsel them with acute intelligence rivaling their offspring’s.

កញ្ញា **ម៉ា ឈិត ស៊ូ វីន** (Daw Ma Chit Su Win)

ខ្ញុំបានធ្វើខុសចំពោះបិតារបស់ខ្ញុំយ៉ាងច្រើនណាស់ ចាប់តាំងពីខ្ញុំអាយុប្រាំឆ្នាំមកម្ល៉េះ។ គាត់តែងតែជេរប្រទេចខ្ញុំ។ ព្រះតេជគុណចូរព្រះអង្គផ្តល់ឱវាទដល់ខ្ញុំផង។ បញ្ហាមិនប្រសើរសោះរវាងឪពុកខ្ញុំនិងខ្ញុំ។ ហើយម្តាយខ្ញុំរស់នៅឆ្ងាយ។ ពុកតែងតែរអ៊ូព្ទេ១ថា "ខ្ញុំចិញ្ចឹមកូនឯងតាំងពីតូចមក ប៉ុន្តែ កូនឯងបែរជាស្រឡាញ់ម៉ែច្រើនជាង"។ ព្រះតេជគុណ, នោះមិនពិតទេ។ ខ្ញុំស្រឡាញ់ពុកម៉ែទាំងពីរស្មើគ្នា។ ខ្ញុំចង់ទទួលនូវសេចក្តីស្រឡាញ់ដ៏ស្ងប់ពីបិតា។ ខ្ញុំគ្រាន់តែនិយាយថា "ចាស៎ ចាស៎" ទៅគាត់។ ដូច្នេះ សូមព្រះតេជគុណជួយសុំឱ្យខ្ញុំផង។

I am supposed to have done many, many wrongs to my father since the age of five. He is always scolding me. Admonish me, Venerable Sir. Things do not go well between father and me. And mother is at a far away place. Father always thinks aloud, “I have brought you up all along, yet you love mother more”. That is not true, Venerable Sir. I love both Father and Mother. I would like to receive calm and peaceful love from Father. I just say “yes, yes” to him. So please intercede, Venerable Sir.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

អ្នកមើលគ្រួសារតែមួយផ្នែក និងមិនមែនពីរផ្នែកឡើយ។ ពុកម៉ែ និងកូនចាត់ទុកជាពីរផ្នែក។ អ្វីដែលម្តាយឪពុកនិយាយ គឺត្រឹមត្រូវ អ្វីដែលកូន១និយាយក៏ត្រឹមត្រូវដែរ។ ពួកគេទាំងអស់សុទ្ធតែនិយាយចេញពីដួងចិត្ត។ ការនិយាយជាមួយមាតាបិតាខ្ញុំប្រើពាក្យគួរជាទីរីករាយតាងនាមឱ្យកូន១។ ពេលនិយាយជាមួយកូន១ ខ្ញុំជជែកការពារតាងនាមឱ្យមាតាបិតា។ នេះជាធម្មជាតិ និងទំនៀមទម្លាប់របស់ខ្ញុំ។ ខ្ញុំមិនសង្កត់ទៅផ្នែកនេះ ឬប៉ែកខាងណោះទេ។ ពាក្យទូន្មាន ដោយយើងជាព្រះសង្ឃច្បាស់ជាមានប្រសិទ្ធ-ភាព។ ចូរមើលចុះ! អ្នកទាំងពីរក្រុម ម្តាយឪពុក និងកូន។ មុន និងក្រោយជួបខ្ញុំ បណ្តាលឱ្យមានភាពផ្សេងគ្នានៅក្នុងចិត្តរបស់អ្នក រួច

ទៅហើយ។ ទាក់ទងតាមផ្លូវចិត្ត អ្នកទាំងអស់គ្នាកាន់តែឆ្លាតទៅៗ កាន់តែយល់ដឹងច្រើនឡើងៗ។

See the family as one front, and not two. Parents and children could be deemed two fronts. What parents say is right; what children say is also right. They all say from the heart. Speaking with parents, I use pleasing speech on behalf of children. When speaking with children, I plead on behalf of parents. This is my nature and custom. I don't stick to this side or that. Admonition by us saṅgha could be effective. Look, you two groups of parents and children. BEFORE and AFTER meeting with me have caused a difference in your mentality. Concerning the mind, all become more intelligent, more understanding.

មានវត្ថុជាច្រើនត្រូវតែធ្វើដោយប្រពៃ និងវត្ថុផ្សេងទៀតគួរតែចៀសវាងដោយប្រពៃ។ ចូរកុំសម្តែងអាកប្បកិរិយា ឬនិយាយដោយគំរោះគំរើយឡើយ។ ប្រសិនបើ មិនអ៊ីចឹង អ្នកដើរចេញឱ្យឆ្ងាយទៅ។ រវាងឪពុកម្តាយ និងកូន កូនៗហាក់បីដូចជាចូលចិត្តធ្វើ ឬនិយាយឈ្លើយទៅកាន់មាតាបិតា។ អាកប្បកិរិយាបែបនេះមិន-មែនទាក់ទងនឹងជនដែលមិនជាទីស្រឡាញ់ឡើយ។ អ្នកខ្លះគ្មានចិត្តស្រឡាញ់ចំពោះអ្នកដទៃ ម្ល៉ោះហើយធ្វើ ឬនិយាយដោយគំរោះគំរើយ។ ភាពទន់ខ្សោយនេះមានច្បាស់ខ្លាំងណាស់សម្រាប់កូនៗ។

ប្រធានបទរបស់ខ្ញុំថ្ងៃនេះ គឺ ចូរកុំធ្វើ ឬក៏និយាយច្រឡើសបើស។ នៅពេល កូនចៅក្លាយជាឪពុកម្តាយគេ អាកប្បកិរិយាច្រឡើស-បើសនេះ ត្រូវចុះខ្សោយច្រើនណាស់ ទោះបីជា វាមិនបានដកចេញអស់ទាំងឫសក៏ដោយ។

There are many things worthy of doing and things worthy of shunning. Do not act or speak perversely; if not, you go away. Between parents and children—children are more likely to act or speak perversely, to their own detriment. This behaviour is not concerned with unloved. Some, not conscious of their love for others, act or speak perversely. This weakness holds very true for children. My theme today--Don't act or speak perversely. When offspring become parents, the perverse attitude is much lessened, if not completely rooted out.

មានធម្មជាតិច្រឡើសបើសជាច្រើនទៀត ជារឿយៗ កូនចៅគឺគ្មានការព្រមព្រៀងជាមួយម្តាយឪពុក។ ខ្ញុំជាមនុស្សអាចនៅទាំងពីរផ្នែក-មាតាបិតា និងកូន។ ការមើលងាយប្រមាទកូនចៅជាផ្នែកមួយ មាតាបិតាចម្រើននូវទម្លាប់អាក្រក់។ ចូរនិយាយមើល ពុកម៉ែទាំងពីរនាក់ដែលអង្គុយនៅក្បែរគ្នា ចូរសួរកូនប្រុស ឬកូនស្រីមើលថា តើម្តាយឪពុកមួយណាដែលស្រឡាញ់ច្រើនជាង?។ តើពួកគេ

របៀបចំចម្លើយដោយរបៀបណា? ។ សូមរង់ចាំមួយស្របក់ ។ កូនក៏មុខជាគិត "ពួកគេច្បាស់ជាស្រឡាញ់ពុក ឬម៉ែច្រើនជាង វាជារឿងសាមញ្ញ" ។ តើពុកម៉ែធ្វើអ៊ីចឹងទេ? ។ វាស្ទើរតែគ្រប់គ្នាហើយ ។ ចូរគ្រប់គ្រងកូនរបស់អ្នកចាប់តាំងដំបូងមក ដោយនិយាយថា "ចូរស្រឡាញ់ពុក និងម៉ែស្មើគ្នាណាកូន" ។ រក្សាភាពស្មើគ្នាណាកូន ។ បើមិនដូច្នោះទេ កូនប្រុស ឬកូនស្រីចាប់ផ្តើមមានទស្សនៈថា ពុកម៉ែច្បាស់ជាត្រូវស្រឡាញ់ច្រើនជាង ។ បន្ទាប់មក គាត់ ឬនាងគិតថា "ខ្ញុំគួរស្រឡាញ់នរណាដែលឱ្យលុយខ្ញុំច្រើន សេចក្តីសប្បាយច្រើន ឬស្នាមញញឹម" ។ តាមមាគ៌ានេះ ពុកម៉ែមួយរូបមិនទទួលបាននូវសេចក្តីស្រឡាញ់ដូចគ្នា នឹងអ្នកម្ខាងទៀត ពីកូនឡើយ ។

With more of a perverse nature, offspring are often in disagreement with parents. I for one could be on either side--of children or of parents. Looking upon offspring as one side, parents develop a bad habit. Say, two parents sitting side by side ask a son or daughter which parents he/she loves more. What answer can they manage? Let's leave it awhile. The children also come to think, 'Father/Mother must be loved more: it is normal'. Did parents act thus? Virtually every one. Control your children from the beginning, saying: Love Father and Mother equally. Stick to fairness. If not, a son/daughter begins to have the concept that one parent must be loved more that the other. Then he/she thinks, 'I should love the one who gives me more pocket-money, more favours, or keeps a smiling face'. In this way a parent doesn't receive the same love as the other from their children.

ដូច្នេះ ពីដើមដៃ ចូរកុំបង្រៀនកូនឱ្យមានការប្រកាន់, ចូរបង្រៀនពួកគេឱ្យស្រឡាញ់ពុកម៉ែស្មើគ្នា ។ អ្នកទើបតែនិយាយមិញថា ការយល់ដឹងគឺសំខាន់ណាស់ ។ ប៉ុន្តែ តើយល់របៀបណា? ។ ចូរកុំចាត់ទុក ចិត្តរបស់កូនចៅយ៉ាងនេះ ឬចិត្តរបស់ឪពុកម្តាយអ៊ីចេះឱ្យសោះ ។ ផ្នែកទាំងសងខាងគប្បីយកចំណុចនេះដាក់ក្នុងចិត្ត ។ តាមតថភាពពិត មាតាបិតាដែលចាប់ផ្តើមមានបុត្រ គិតត្រឹមតែបុត្រប៉ុណ្ណោះ, រីឯកូនវិញ តាំងទារកភាពមកគិតត្រឹមតែមាតាបិតារបស់គេប៉ុណ្ណោះ ។ ប៉ុន្តែ នៅតែមានកូនមួយចំនួនពឹងផ្អែក ឬផ្តល់នូវការគោរពដល់ឪពុកម្តាយម្នាក់, ម្តាយ ឬឪពុក ច្រើនជាង ។

Therefore, from the beginning don't teach the children to be discriminative; teach them to love both parents equally. You just said understanding is crucial. But how? Don't regard the mentality of offspring as such, or the mentality of parents as such. Both sides should take this to heart. In reality, parents starting to have children only think in terms of their children. Children since their infancy only think in terms of their parents.

Still, some children are more dependent on, or give more regard to, a parent, i.e Mother or Father.

ភាពទន់ខ្សោយនេះ កើតនៅលើផ្នែកទាំងពីរនៃឪពុកម្តាយ និងកូន។ វាមានសារៈសំខាន់ណាស់ក្នុងការកែនូវភាពទន់ខ្សោយ។ អ្នកនិយាយថា "ខ្ញុំនឹងរៀននូវការអត់ឱនទោស" ប៉ុន្តែទាំងនេះគឺគ្រាន់តែជាពាក្យសម្តីប៉ុណ្ណោះ។ បញ្ហាគឺនៅត្រង់ថា អ្នករាល់គ្នារិះគិតនូវអ្វីដែលគាត់ ឬ នាងកំពុងតែធ្វើ គឺត្រឹមត្រូវជានិច្ច ហើយអ្វីដែលគាត់ឬនាងធ្វើ និយាយ និងគិត ដោយបំណងល្អ។ ដូច្នេះ ចូរគិតម្តងទៀត ពុកម៉ែ និងកូនៗ ចូរភ្ជាប់នូវផ្លូវរបស់អ្នក ប្រសិនបើ អ្នកទាំងអស់គ្នាត្រូវតែធ្វើដំណើរទៅ។ ខ្ញុំនឹងនិយាយអំពីសង្គហធម៌របស់មាតាបិតា និងសង្គហធម៌របស់កូន នៅពេលខាងមុខ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង បានសម្តែងអំពីសង្គហធម៌របស់ឪពុកម្តាយ និងសង្គហធម៌របស់កូនយ៉ាងពិស្តារ។

This weakness happens on both sides of parents and children. It is only essential to correct the weakness. “I will exercise toleration”, you said but they are only words. Trouble is--everybody thinks what he/she is doing is right always and what he/she does, speaks and thinks is due to good intention. So, think again; parents and children--mend your ways if you have to. I will speak about the qualities required of parents, and of children, in future. Our Lord Buddha had taught completely the qualities required of parents and children.

## ផ្នែកទី៣ (B)

## Part III (B)

កញ្ញា **ម៉ា អេង ភូ ភូ អោង** (Daw Ma Eint Phu Phu Aung)

គ្រួសាររបស់យើងមិនដែលមានការឈ្លោះប្រកែកគ្នា ដោយ-សាររឿងផ្ទាល់ខ្លួនទេ។ នោះក៏មិនមែនមានន័យថា សេចក្តីស្ងប់តែងតែកើតមាននៅក្នុងគ្រួសារនោះដែរ។ ភាពលំបាកពិតជាកើតឡើងពិតប្រាកដ ជាពិសេស រវាងបងស្រីរបស់ខ្ញុំ, ខ្ញុំ និងម៉ែ។ ទាក់ទងនឹងពេលខ្លះ ម៉ែហាក់បីដូចជាមានឥទ្ធិពលដោយងងឹតងងុល។ ដូច្នេះយើងនិយាយឡើងដោយភ័យខ្លាចពីប៉ែកខាងម្តាយ។ តាមពិតទៅយើងត្រូវរងទុក្ខ ដោយភ័យខ្លាចម៉ែធ្វើឱ្យស្លុតចិត្ត និងមិនសប្បាយចិត្ត។ រឿងនេះ ម៉ែច្បាស់ជាមិនដឹងទេ។ ម៉ែអាចផ្តល់នូវឧទាហរណ៍ច្រើនណាស់ ដើម្បីពន្យល់នូវបញ្ហា ប៉ុន្តែយើងមិនអាចទេ។

Our family never had quarrels on account of personal affairs. That does not mean peace exists always at home. Difficulties do arise, especially between my sister and I and Mother. Concerning

some circumstances, Mother tends to pretend to be ignorant. So we speak up, for fear of suffering on Mother's part. Indeed, we had had to suffer, fearing Mother would have been depressed and looked unhappy. This she would not have been aware of. Parents could bring up many examples to explain things, but we could not.

អ្នកស្រី **មូ មូ សេខ** (Daw Mu Mu Shein)

ខ្ញុំមានកូនចៅបីនាក់។ ក្នុងភាពយុវជនរបស់ពួកគេ អ្វីៗប្រព្រឹត្តទៅយ៉ាងល្អ។ មិនដូចជាតុក្កតាជ័រឡើយ ខ្ញុំមិនបានរាប់អានស្រឡាញ់ពួកគេ ដោយភាពទន់ភ្លន់រហូតទេ។ ខ្ញុំគិតថា ពួកគេគួរតែយល់ពីបំណងរបស់ខ្ញុំ ដែលចង់ឱ្យពួកគេល្អ អនាគតល្អ។ ខ្ញុំមានមហិច្ឆតាណាស់ ខ្ញុំបានចូលរៀននូវវគ្គសិក្សាផ្សេងៗ ដោយមានចំណងតែមួយគត់ គឺដើម្បីឱ្យមានសមត្ថភាពចិញ្ចឹមកូនៗ នាពេលអនាគត។ ប៉ុន្តែ អម្បាញ់មិញ កូនស្រីរបស់ខ្ញុំនិយាយសំដៅមកខ្ញុំតែម្តង ដោយនិយាយថា ខ្ញុំមានឥទ្ធិពលលើពួកគេទាំងងងឹតងងុល។ នាងបាននិយាយវា នៅក្នុងបរិបទមួយនៃសាច់ញាតិ ពោលគឺម្តាយរបស់ខ្ញុំ ឬយាយរបស់នាង។ នោះគឺគ្រាន់តែជាការគិតរបស់នាងទេ។ ពួកគេហាក់បីដូចជាគិតថា ខ្ញុំកំពុងតែឱ្យអត្ថិភាពដល់អ្នកដទៃជាងកូនរបស់ខ្លួន។ ឬដូចជាថា ខ្ញុំមិនដឹងពីបំណងអាក្រក់របស់អ្នកដទៃ ប្រឆាំងនឹងរូបខ្ញុំទេ។ ខ្ញុំពិតជាដឹងច្បាស់ណា ប៉ុន្តែ ខ្ញុំបង្រៀនពួកគេនូវអំពើល្អនៃភាពអត់ឱន។ បញ្ហានេះ ពួកគេមិនយល់ទេ។

I have three offsprings. In their youth things went well. Unlike plastic toys, I did not treat them gently always. I had thought they would have understood my intentions were meant for their good, their progress later in life. I had been ambitious: I attended various training courses even while single with the intention of bringing up able children later. Still, my daughter referred to me just now, saying I was affecting ignorance. She meant it in the context of a close relative, that is, my mother--or her Grandmother. That is only her thinking. I am giving priority to outside persons rather than my children, they seem to think. Or, like, I am unaware of others' ill intention against me. I do know, but I only teach them the goodness of tolerance. This they do not understand.

មួយវិញទៀត ខ្ញុំចង់លើកយកប្រធានបទថ្មីមួយឡើង។ ខ្ញុំច្រើនគិតថា ពេលណាកូនចៅរបស់យើងមានប្រាជ្ញាមុតស្រួច និងវៃឆ្លាត យើងនឹងនៅពីក្រោយម្តង។ ខ្ញុំចង់និយាយពីឪរបស់នាង និងកុំព្យូទ័រ។ មានអ៊ីនធឺណែត ដែលខ្ញុំតែងតែយល់មិនដល់ភាសារបស់គេទេ។ នៅពេលខ្ញុំសួរកូនខ្ញុំ ពួកគេគ្មានភាពអត់ធ្មត់ទេ ហើយនិ-

យាយវ៉ូងវ៉ាង។ ជាមួយក្រសែភ្នែកដ៏គួរឱ្យអាណិត ខ្ញុំមិនអាចប្រើខ្ទង់សម្រាប់ចុច (Keyboard) នេះបានល្អទេ។ ដូច្នេះ ខ្ញុំកំពុងរៀនពីការប្រើកុំព្យូទ័រ ហើយបន្ទាប់មក រៀនសន្ទនាភាសាអង់គ្លេស។ តើព្រោះហេតុអ្វីទៅ? ពីព្រោះ ខ្ញុំមិនចង់ល្ងង់ខ្លៅទេ ជាពិសេសនៅមុខកូនៗ។ ជាការពិតណាស់ វាខុសគ្នាដាច់ស្រឡះពីអតីតកាល ពេលដែលដឹងនូវអ្វីៗ ហើយពួកគេទទួលនូវអ្វីដែលខ្ញុំបាននិយាយ។

Again, I would like to bring up a new subject. I would like to think that as our offspring become sharper and cleverer, we are left behind time and again. I mean her father and computer. There is internet, of whose language I often fail to understand. When I put questions to my children, they are impatient and blurt out. With poor eyesight, I cannot use the keyboard very well. So, I am training for computer use, and then English speaking. Why? Because I do not want to be ignorant of things especially before the children. It was, of course, different in the past, when I seemed to know everything and they were ready to accept what I said.

ឥឡូវនេះ ខ្ញុំហាក់បីដូចជាគ្មានប្រយោជន៍អ្វីទៀតទេ ហើយកូនៗតែងតែសើចដាក់ខ្ញុំពីក្រោយខ្នង។ ឥឡូវការរិះគិតរបស់ខ្ញុំចេះតែវែងឆ្ងាយទៅៗ ខណៈនេះខ្ញុំនៅមានកម្លាំង និងធ្វើការងារបានពួកគេចាត់ទុកខ្ញុំស្មើពួកគេ ស្មើនឹងឋានៈពួកគេដែរទៅហើយ។ ដូច្នេះខ្ញុំត្រូវតែសិក្សាជានិច្ច។ ប្រសិនបើ មិនអីចឹងទេ ពួកគេតែងតែធ្វើដំណើរទៅមុខ ហើយយើងនឹងត្រូវទុកនៅពីក្រោយកាន់តែឆ្ងាយទៅឆ្ងាយទៅ។ សព្វថ្ងៃនេះ ខ្ញុំមានអាយុ ៥0 ឆ្នាំ ហើយនៅអាយុ ៦0 ៧0 ឆ្នាំ យើងប្រាកដជាងងឹតភ្នែក សក់ស្កូវ និងធ្មេញបាក់។ នៅពេលយើងមិនអាចធ្វើអ្វីកើតទៀត តើយើងគួរនឹងធ្វើអ្វីដើម្បីពួកគេនៅក្នុងអនាគតកាល?

Now, I seem to be useless, and the children are often laughing at me behind my back. Now my thinking goes, like, while I am still up and working I am determined to keep abreast of them, to be on equal terms with them. So I am under constant training. If not, they are always progressing and we are being left further and further behind. Now in our fifties and at 60, 70 we would be virtually blind, with grey hair and broken teeth. When we cannot be up and about in future what shall we do to relate to them?

លោក **ម៉ាហ្គ ស៊ិ ធូ អោង** (U Mg Si Thu Aung)

ព្រះតេជគុណ! សូមអនុញ្ញាតឱ្យខ្ញុំពន្យល់។ អ្វីដែលយើងចង់ឃើញ នៅផ្នែកមាតាបិតាគ្មានសមត្ថភាព។ យើងមិនទទួលយកបានទេ ដែលថា មាតាបិតាត្រូវតែចេះប្រើកុំព្យូទ័រនោះ។ ចុះតើមា-

តាបិតានៅឯជនបទយ៉ាងណាវិញទៅ? ពួកគេប្រឹងប្រែងធ្វើការងារយ៉ាងលំបាកដោយដៃ ដាំដំណាំស្រែចំការ ដើម្បីឱ្យមានសមត្ថភាពបញ្ជូនកូនទៅរៀននៅទីក្រុង។ ប៉ុន្តែ ដោយសារប្រឹងប្រែងរកប្រាក់ដ៏លំបាក ដោយញើសឈាម ពួកគេបញ្ជូនកូនៗមកសិក្សានៅរាជធានី។ មិនដូចជាប្រជាជន នៅរាជធានីទេ ពួកគេយល់ពីបំណងដ៏ល្អបំផុតរបស់ពុកម៉ែទាំងសងខាង។

Let me explain, Venerable Sir. What we should like to see in parents is not ability. We do not accept that parents must be able to use the computer. What about the parents in the countryside? They work hard on land to raise crops so that their children could be sent to big towns for schooling. But, with their hard-earned money through blood and sweat they send the children to cities for education. Unlike people in the cities, the best intention of parents are understood on both sides.

ប៉ុន្តែ ជួនកាលមាតាបិតាអាចប្រែរជាមានកំហឹងលើកូនមួយចំនួន ដោយសារការបរាជ័យពាណិជ្ជកម្ម ឬការឈ្លោះប្រកែករវាងឪពុកម្ដាយខ្លួនឯង។ ស្ថានភាពបែបនេះ មិនមែនអាចជាបញ្ហាមួយដង ឬពីរដងទេ។ ប៉ុន្តែ ការមានមានៈនេះ ជាផ្ទាំងស៊ីប កូនដែលមិនរីករាយអាចប្រែរជាមានគំនិតអវិជ្ជមានទៅវិញ។ ជាចម្បងអ្វីដែលយើងជាកូនចង់បានពីមាតាបិតា គឺស្រឡាញ់ដ៏ជ្រាលជ្រៅ និងបរិសុទ្ធ។ ប្រសិនបើ វាកើតឡើងបាន បរិយាកាសនៃគ្រួសារគឺជាជំហានបន្ទាប់ ផ្ដល់នូវសុភមង្គលដោយខ្លួនវា។ ជាក់ស្ដែង កូនចៅទាំងអស់ស្រឡាញ់មាតាបិតារបស់គេ ហើយដូចទៅនឹងអ្វីដែលប្អូនស្រីខ្ញុំបាននិយាយអម្បាញ់មិញ ពួកគេមិនដឹងថា តើត្រូវធ្វើអ្វីឡើយ ប្រសិនបើ មាតាបិតាកើតទុក្ខក្រៀមក្រំ។ ហើយពួកគេមិនដឹងថា តើត្រូវបញ្ចេញសម្លេងអំពីដួងចិត្តរបស់គេដោយរបៀបណា។

But sometimes a parent might turn his/her anger on some of the children, because of failing business or of quarrels between the parents. Such circumstances may not matter one or two times. But this persisting, the targeted, displeased child might come to have negative ideas. In the main what we children want from parents is deep and pure love. If it happens always, circumstances of a family are secondary to its happiness. Virtually all offspring love their parents, and, like my sisters just said, they do not know what to do if a parent looks depressed. And they do not know how to articulate about their heart.

ប៉ុន្តែ មាតាបិតា គឺជាអ្នកចាស់ទុំ ដោយចំណេះដឹងច្រើនខាងពុទ្ធវចនៈ អាយុកាល និងបទពិសោធន៍ នៅខាងផ្នែករបស់គេ។

ដូច្នេះ ពួកគេគួរគប្បីផ្តល់នូវគំរូ បន្ទាប់ពីគំរូនឹងហើយ ដែលបណ្តាលឱ្យមាត់របស់យើងបិទជារៀងរហូតទៅ។

But parents are seniors with a lot of knowledge in Buddhist literature, and advanced age and experience on their side. So they would give example after example causing our mouths to remain closed.

អ្នកស្រី **ម៉ា ស៊ូ ធិត មុន** (Daw Ma Su Thet Mon)

តាមពិតទៅ ការយល់គ្នារវាងមាតាបិតា និងកូនចៅ គឺសំខាន់ណាស់។ នៅក្នុងស្ថានភាពជាក់ស្តែង យើងយល់ព្រមតាមសេចក្តីប្រាថ្នារបស់កូនៗទាំងអស់ ប៉ុន្តែ ពួកគេគ្មានផ្តល់នូវភាពកក់ក្តៅវិញឡើយ។ ពួកគេមិនចេះយល់ចិត្តពួកយើង ឬសូម្បីព្យាយាមយល់។ ពួកគេគួរគប្បីគិត តើពាក្យរបស់ខ្ញុំនឹងធ្វើកូនឈឺចាប់ឬ ព្រះតេជ-គុណ? តើគួរឱ្យខ្ញុំប្រើពាក្យគំរោះគំរើយ ឬពាក្យទន់ភ្លន់?

Understanding between parents and offspring is necessary, indeed. In certain situations we comply with all their wishes, but they did not return the favour in their turn. They do not empathize with us, or even try to. They should think, Venerable Sir, like, will my words hurt the children? Should I use harsh or pleasing words?

លោក **ថាន់ ម្មិន** (U Than Myint)

ព្រះតេជគុណ យើងឃើញថា ពីរក្រុមមានទស្សនៈផ្សេងគ្នា។ ខ្ញុំចង់និយាយតាងនាមឱ្យខាងមាតាបិតាទាំងឡាយ។ យើងអាចមានលោភៈ ទោសៈ មោហៈ ប៉ុន្តែ វាគឺសម្រាប់ប្រយោជន៍របស់កូនហ្នឹងឯង។ ពួកគេនឹងមើលខាងមាតាបិតាពីទស្សនវិស័យពីរប្រការ គឺៈ សេដ្ឋកិច្ច និងការអប់រំ។ មាតាបិតាច្បាស់ជាខ្សោយនូវផ្នែកទាំងពីរ ឬផ្នែកមួយ។ ធម្មជាតិនៃសមាជិកនៅក្នុងជីវិតជាគ្រហស្ថមានរឿងដ៏ចាស់ទុំមួយ។ វត្ថុដែលយុវជនពេញចិត្ត គឺផ្សេងពីវត្ថុដែលក្មេងៗចូលចិត្ត។

Venerable Sir, we see two groups, different views. I would like to speak on behalf of parents. We might have greed, anger, bewilderment, but it is for children’s sake. They will look on parents from two perspectives: economic and educational. Parents may be weak in both, or in one. Dispositions of members in a household have an old history. Things liked by adults are different from those liked by children.

ដូច្នេះ កូនៗនឹងយល់នូវបញ្ហានេះ ពេលពួកគេក្លាយជាឪពុកម្តាយនាពេលអនាគត។ យើងទាំងអស់គ្នាមកឃើតសម្រាប់ការពិ-ភាក្សានេះ ដូច្នេះ ខ្ញុំគិតថា កូនៗនឹងយល់នៅពេលក្រោយ។ យើង

នឹងដាក់ការពិភាក្សានេះដើម្បីអនុវត្ត។ ប្រសិនបើ ពេលនេះកូនៗមិនជឿទេ ពួកគេនឹងជឿយ៉ាងពិតប្រាកដ នៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ។

As such, children will come to understand this when they become parents in future. We came together late for these discussions, so I think children will come to understand later. We are putting the deliberations to practise. If children are not convinced yet, they surely will be in their married life.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

សូម្បីតែថ្ងៃម្សិលមិញ ខ្ញុំបានសម្តែងពីចំណុចនោះដែរ។ កូនៗជាមនុស្សពេញវ័យ នឹងពឹងផ្អែកលើមាតាបិតា រីឯមាតាបិតាវិញ ជារាមច្បងលើកូនចៅរបស់ពួកគេ។ អ្វីៗនឹងប្រព្រឹត្តទៅយ៉ាងប្រពៃនៅរយៈពេលទាំងពីរនេះ។ តើនៅពេលណា ទើបបញ្ហាទាំងនេះភ្លាត់ពីផ្លូវ?។ វា គឺនៅពេលដែលកូនចៅមានអាយុស្រេបាលនេះ ចំណែកឯមាតាបិតាក៏ទើបមានអាយុពាក់កណ្តាលមនុស្ស តើវាអ៊ីចឹងមែនឬទេ?។ ចូរពិចារណាឱ្យបានប្រពៃ។ មិនទាន់ចាស់នៅឡើយទេ មាតាបិតាត្រិះរិះពិចារណាដោយពួកគាត់ផ្ទាល់ថា នៅមានសមត្ថភាព។ ឥឡូវនេះ កូនចៅចង់បានសិទ្ធិដាច់មុខនៃការពិចារណាដោយពួកគេទៅហើយ។ នេះហើយដែលការប៉ះទង្គិចគ្នាកើតឡើង។

Even yesterday I discoursed on that point. Children as adolescents will depend on parents; parents as the elderly on their offspring. Things will go well during the two periods. When do things go off track? It is when offspring have just come of age and the parents are still in middle age. Isn’t it so? Consider it well. Not yet old, the parents consider themselves still capable (their prerogative). The offspring now aspire to the prerogative of deciding by themselves. Here’s the clash happening.

ដូច្នេះ មាតាបិតាច្បាស់ជាស្រឡាញ់ស្នេហាចំពោះ ឬទុកចិត្តទៅលើកូនរបស់ពួកគេ។ ផ្ទុយទៅវិញ ឥឡូវនេះកូនចៅដែលក្លាយយុវវ័យច្បាស់ជាគិតយ៉ាងប្រពៃ ដោយភាពប្រាកដប្រជានូវពាក្យទូន្មានរបស់មាតាបិតា ទោះជាខ្លីឬវែង ពីព្រោះពាក្យទូន្មានមាតា-បិតានីមួយៗមានបំណងដ៏ល្អចំពោះកូនៗ។ ចូរមើលចុះ! មាតាបិតាម្នាក់អាចប្រើប្រាស់នូវគ្រឿងស្រវឹង ជក់បារី ឬហូបម្លូស្លា ប៉ុន្តែ ពួក-គេមិនដែលលើកទឹកចិត្តកូនៗរបស់គេ ឱ្យយកតម្រាប់តាមទម្លាប់អាក្រក់របស់គាត់ឡើយ។ កូន! ចូរអ្នកយល់ពីទឹកចិត្តមេត្តារបស់មាតាបិតាអ្នក។ ចូរអ្នកមានស្មារតីជានិច្ចថា បិតា គឺនៅជិតនូវភាព-

ទន់ខ្សោយ។ មាតាបិតាដែលចាប់ផ្តើមមានភាពទន់ខ្សោយ គឺត្រូវប្រឈមមុខនឹងសេចក្តីទុក្ខផងដែរ។

So, parents may well be more affectionate towards or reliant on their children. In turn, the offspring, being adults now, may well regard with seriousness any admonition by the parent--be it short or long, because any parental advice is well intentioned for the children. See---a parent may use intoxicating drinks, smoke or chew the betel quid, but they never encourage their children to adopt their bad habits. Children, may you understand the parents' *mettā*. Be also mindful that Father is close to debility. Parents starting to have debility are also stricken with grief.

នៅគ្រាមួយ កូនៗមកដល់ភាពយុវភាព មាតាបិតាព្រួយបារម្ភថា កូនៗនឹងមិនយកពាក្យពេចន៍មកគិតពិចារណាឡើយ។ ពួកគេមានអារម្មណ៍ថាៈ ខ្ញុំគ្មានឥទ្ធិពលទៀតទេ។ ខ្ញុំត្រូវតែបណ្តោយឱ្យពួកគេ ទៅធ្វើអ្វីដែលគេពេញចិត្តចុះ។ ពួកគេហួសពីការគ្រប់គ្រងហើយ។ មាតាបិតាមានជម្ងឺវិកលចរិក ចាប់ផ្តើមមានភាពសង្ស័យនិងលែងមានជំនឿលើកូនរបស់គេទៀតហើយ។ កូនៗ ចូរអ្នកចែករំលែកអារម្មណ៍របស់ពួកគាត់ផង។ មាតាបិតាប្រហែលជាគ្មានម្ចាស់ការលើខ្លួនឯង ក្នុងការអប់រំកូនរបស់គេ ហើយអាកប្បកិរិយាអវិជ្ជមានរបស់គាត់លេចចេញឡើង។

Once the children reach adulthood parents worry that their words would not be taken into account by children. They also feel: I have no more influence. I must let them go to do what they like. They are out of control. Parents with this psychoneurosis begin to have doubts and disbelieve their children. Share their feelings, children. Perhaps parents have no more self-confidence in admonishing their children, and their negative attitude appears.

ផ្នែកខាងកូនៗវិញគ្រាន់តែគិតថាៈ ពុក ឬម៉ែមិនជឿខ្ញុំទេ។ ពួកគាត់ នឹងមិនចាំបាច់ព្យាយាមកែតម្រូវបញ្ហានេះទេ ឬខំពុះពារទៅវិញ នូវជំនឿរបស់មាតាបិតា។ ផ្ទុយទៅវិញ ពួកគេចាប់ផ្តើមធ្វើអាកប្បកិរិយាច្រឡើសបើស។ តាមពិតទៅ គ្មានបុគ្គលណាមួយត្រូវស្តីបន្ទោសឡើយ ទោះពុកម៉ែ ឬកូនចៅ។ ប្រសិនបើ មានការស្តីបន្ទោស នោះវាមិនមែនកំពុងតែតភ្ជាប់ផ្លូវរបស់ខ្លួនទេ មិនអ៊ីចឹងឬ?។ អ្នកច្បាស់ជាដឹងនូវភាពទន់ខ្សោយរបស់អ្នកគ្រប់គ្រាន់ ក្នុងការណែនាំពួកគេហើយ។ ខ្ញុំគ្រាន់តែចង្អុលបង្ហាញនូវបញ្ហានេះ ជាការណែនាំដ៏សង្ខេប ក្នុងការយកទៅអនុវត្តតភ្ជាប់ជាក់ស្តែង។

Children on their part only think: Father/Mother does not believe me. They will not try to right this, or to win back their parents' faith in them. Instead they start acting perversely. In reality nobody is to blame, parents or offspring. If there is any blame, it is not mending one's ways. Isn't it so? You might well know your weakness enough to correct them. I only point to this, short of exhorting you to actually carry out the mending.

តើព្រោះហេតុអ្វីទៅ? ខ្ញុំមិនជម្រុញឱ្យបុគ្គលណាមួយដែលនៅងាប់ នឹងមាគ៌ាអាក្រក់នោះឡើយ ។ បុគ្គលពាលបែបនេះ គឺនៅច្រំដែលៗហ្នឹងឯង ពោលគឺ គាត់ ឬនាងដឹងកាន់តែច្រើន គាត់ ឬនាងក៏កាន់តែមានភាពច្រឡើសបើសច្រើនឡើង ។ ហើយរឹងរឹតតែឆ្កួតថែមឡើងទៀត ។ មាគ៌ានេះនាំឱ្យបរាជ័យនៃកូនទូទៅប៉ុណ្ណោះ មិនមែនពុកម៉ែទេ ។ នៅក្នុងគ្រួសារមួយ កូនដែលមានស្មារតីខ្ពស់នឹងមិនព្យាយាមធ្វើឱ្យមាតាបិតាពិបាកឡើយ រីឯមាតាបិតាវិញ ក៏នឹងមិនព្យាយាមធ្វើឱ្យកូនមិនសប្បាយចិត្តដែរ ។ ទាំងអស់នេះហើយដែលខ្ញុំចង់និយាយ ។

Why? I dare not urge one who still sticks to bad ways. Such a fool is repetitive: the more he/she knows, the more perverse he/she becomes. And more foolish. This route leads to general failure of children only, not of parents. With a family spirit children will try not to displease parents, and parents won't try to make children unhappy. That is all I want to say.

សូមមាតាបិតាទាំងឡាយកែតម្រូវ នូវភាពទន់ខ្សោយរបស់ខ្លួន និងកូនកែតម្រូវនូវមាគ៌ាខុសរបស់គេ ។ ប្រសិនបើ ធ្វើដូច្នេះបាន គ្រួសារនឹងកាន់តែសប្បាយរីករាយទៅៗ ពីមួយថ្ងៃទៅមួយថ្ងៃ ឬក៏ពេញមួយជីវិតតែម្តង ។ ហើយពេញដោយសេចក្តីស្ងប់ផងដែរ ។ នៅពេលមាតាបិតា និងកូនចៅអាចបង្កើតនូវគ្រួសារដ៏សប្បាយ និងស្ងប់ ខ្ញុំសូមជូនពរឱ្យអ្នកគ្រប់គ្នា ក្លាយជាម៉ែល្អ ឪពុកល្អ កូនប្រុសស្រីល្អ ឬជាធម្មតា ជាបុគ្គលមានសីលធម៌ ។

May parents correct their weaknesses, and children their wrong ways. If so, how happier a family will become from day to day or in their whole life. And peaceful too. As both parents and offspring are capable of creating a happy, peaceful family, I pray: May everyone become a good mother, father, son or daughter, or, simply put, one of the virtuous.

## **ផ្នែកទី ៤**

Part IV

បណ្ដាកត្តានៃការតបគុណទាំងនេះ មានកត្តាប្រាំប្រការដែលបង្រៀនពីរបៀបរក្សានូវចិត្តរបស់អ្នក។ ធម៌ទាំងនោះ គឺៈ-

ក. ការគោរពឱនលំទោន

ខ. សុភាពរាបសា

គ. ការសប្បាយរីករាយចិត្ត

ឃ. ការដឹងនូវឧបការគុណ

ង. ការស្ដាប់ព្រះធម៌តាមសមគួរដល់ពេលវេលា

Among these Factors of Auspiciousness there are five which teach how to keep your mind. They are:

- a- To be respectful,
- b- To be modest,
- c- To be contented,
- d- To be grateful,
- e- To listen to the Dhamma at appropriate times.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

ពាក្យទូន្មាននៃព្រះសម្មាសម្ពុទ្ធជាម្ចាស់របស់យើង រួមមានដំបូន្មាន ស្ដីពីការទំនាក់ទំនងរវាងមាតាបិតា និងកូន, ទំនាក់ទំនងរវាងប្ដី និងប្រពន្ធ, ទំនាក់ទំនងរវាងគ្រូ និងសិស្ស, ទំនាក់ទំនងរវាងអ្នកដឹកនាំ និងប្រជារាស្ត្រ, ទំនាក់ទំនងរវាងចៅហ្វាយនាយ និងអ្នកបម្រើ ជាដើម។ ការយល់ពីទំនាក់ទំនងបែបនេះ នឹងញ៉ាំងឱ្យគ្រួសាររីកចម្រើនរុងរឿង ញ៉ាំងសហគមន៍ឱ្យរីកចម្រើនផងដែរ។

Teachings of our Lord Buddha include guidance on relationships between Parents and Children, between Husband and Wife, between Teacher and Pupil, Leader and Follower, Householder and Guest, so on and on. Understanding of such relationships will make for progressive families, progressive communities.

ឥឡូវនេះ មាតាបិតា និងកូនៗកំពុងតែនិយាយទល់មុខគ្នានៅទីនេះ។ ពួកគេកំពុងនិយាយចេញពីចិត្តរបស់ពួកគេ ហើយនឹងបានធូរទ្រូង។ តាមពិតទៅ តាំងពីដំបូងមកម្ល៉េះ កូនប្រុសស្រីទាំងឡាយ គួរគប្បីបំពេញកាតព្វកិច្ច តាមសេចក្ដីប្រាថ្នារបស់មាតាបិតា តាមលទ្ធ-ភាពដែលអាចធ្វើបាន។ មាតាបិតា នៅខាងផ្នែករបស់គេ ក៏គួរគប្បីយល់ពីអារម្មណ៍កូនៗ ហើយធ្វើយ៉ាងណាឱ្យពួកគេសប្បាយ។

Now here, Parents and Children are talking face to face. They are speaking up their minds, and becoming free at heart. In fact, even in the beginning Sons and Daughters should have obliged with the wishes of Parents as much as possible. Parents on their part also should have understood the feeling of Children and opted for making them happy.

ឥឡូវនេះ យើងមានព្រះពុទ្ធសាសនា ជាវប្បធម៌មីយ៉ាន់ម៉ា។ អ្នកអាចនិយាយចេញពីដួងចិត្តរបស់អ្នក ប៉ុន្តែ វាស្ថិតនៅមូលដ្ឋានគ្រឹះនៃសាសនារបស់យើង និងបទដ្ឋាននៅឡើយ។ ឥឡូវតើផ្នែកណានឹងនិយាយមុន?។

Here we have Buddhism, Myanmar culture. You may speak your heart out, but still on the basis of our religion and cultural norms. Now, which side will speak first?

លោក **អោង ថាន** (U Aung Than)

នៅខាងដើមមិញ កូនស្រីម្នាក់បាននិយាយឡើង។ ខ្ញុំស្គាល់ឪពុក និងគ្រួសាររបស់នាង ហើយខ្ញុំអាចយល់ចិត្តគាត់បាន។ ឥឡូវនេះ ខ្ញុំនិយាយតាងនាមឱ្យបិតាទាំងឡាយ ហើយសង្ឃឹមថា កូនៗនឹងយល់ពួកយើង។ យើងជាបុថុជ្ជនទោរមានអត្តចរិត និងការប្រព្រឹត្តិដូចគ្នា ទៅក្នុងអតីតជាតិ លើកលែងតែព្រះសម្មាសម្ពុទ្ធចេញ។ រឿងនេះ ច្បាស់ជាត្រូវណាស់សម្រាប់ឪពុករបស់កូនស្រីនោះ។ ដូចគ្នានេះដែរ កាលពីខ្ញុំនៅពីក្មេង មិត្តភក្តិរបស់ខ្ញុំជានិស្សិតពេទ្យបានមកសួរសុខទុក្ខខ្ញុំអំឡុងពេលវិស្សមកាល។ ឪពុករបស់ខ្ញុំតែងទប់កំហឹងរបស់គាត់ ដែលប៉ងមកលើរូបខ្ញុំ។ គាត់ខឹងនឹងខ្ញុំដែលមិនប្រឹងប្រែងរៀន ឱ្យដល់កម្រិតនឹងក្លាយជានិស្សិតពេទ្យ សូម្បីតែស្ថានភាពគ្រួសាររបស់យើង ប្រសើរជាងស្ថានភាពគ្រួសារមិត្តរបស់ខ្ញុំ។ គាត់នៅតែជេរខ្ញុំ ហើយខ្ញុំដឹងនូវអ្វីដែលគាត់ចង់បានពីខ្ញុំ។ ទន្ទឹមគ្នានេះ តើឪពុកកូនស្រីនោះចង់បានអីពីនាង?

Earlier, a daughter has spoken up. I know her father and family, and could empathize with him. Now I want to speak on behalf of Fathers and hope Children will understand us. Except for Lord Buddha, we worldlings tend to have the same character and conduct as in the past existences. This might be true for that daughter's father. Similarly, when I was young a friend of mine, a medical student, came for a visit during the holidays. My father was barely suppressing his anger, which was aimed at me. He was angry I had not worked enough at school to become a medical student even though our family's circumstances were better than my friend's. He kept scolding me, and I sensed what he had wanted of me. Likewise, what does that daughter's want?

នាងត្រូវតែច្បាស់អំពីបញ្ហានេះ។ ជាឧទាហរណ៍ តើគាត់ខ្វះការយកចិត្តទុកដាក់ ឬយកចិត្តទុកដាក់ជ្រុលពេក?។ បន្ទាប់មក ចូរវិភាគខ្លួនអ្នកផ្ទាល់។ ខ្ញុំបានធ្វើដូច្នេះ ហើយបានយល់ថា ការជេរស្តីរបស់ឪពុក គឺដោយសារតែសេចក្តីរីករាយខ្លាំងរបស់គាត់ ដើម្បីឱ្យខ្ញុំ

ទទួលជោគជ័យ។ ដូច្នេះ គាត់មិនបាននិយាយជាមួយខ្ញុំនឹងពាក្យពេចន៍ទេ ប៉ុន្តែជាមួយនឹងអាកប្បកិរិយាដែលគាត់បានគិតថា ល្អបំផុត។

She has to be clear about it. For example, has he been lacking in care, or over in caring? Then analyse yourself. I did so, and came to understand that Father's scolding was due to his over-enthusiasm to make an achiever of me. So he was speaking to me not with words but with behaviour as he thought best.

ក្រឡេកមើលទៅអតីតកាល ខ្ញុំបានដក់រឿងនេះ ក្នុងដួងចិត្តរបស់ខ្ញុំ ក្នុងការអប់រំទូន្មានកូន។ ប៉ុន្តែ តើត្រូវទូន្មានយ៉ាងដូចម្តេច? ខ្ញុំចង់និយាយថា "ខ្ញុំកាន់តែចាស់ហើយ ធម្មតាសេចក្តីស្លាប់ក៏ខិតមកជិតហើយដែរ។ អ្នកគួរតែក្រោកឈរដោយខ្លួនឯង ព្រមទាំងប្រឹងប្រែងធ្វើការងារឡើង។ ប៉ុន្តែ បញ្ហានេះត្រូវតែធ្វើតាមផ្លូវវាង នេះហើយគឺការទូន្មានបែ៉កខាងខ្ញុំផ្ទាល់។ ជារឿយៗ មានការទូន្មានដដែលៗ ប៉ុន្តែ ការនិយាយច្រំដែលៗអំពីប្រធានបទដូចគ្នា បានធ្វើឱ្យកូនរបស់ខ្ញុំបដិសេធនូវពាក្យទូន្មានរបស់ខ្ញុំ។

Going back to the past, I felt it in my heart to admonish the children. But how? I wanted to say, "I am getting old. Simply put, death is not far away. You shall stand on your own feet, and work hard too. But this had to be done in a roundabout way, that is, admonishment on my own terms. Often there were repeat admonishments, but harping on the same theme made my child to reject my advice.

អ៊ីចឹងទេ មាគ៌ាមួយផ្សេងទៀតនៃការអប់រំរបស់ខ្ញុំ។ នៅផ្ទះសមាជិកគ្រួសារមានការងារច្រើនណាស់ ដូចជា កិច្ចការផ្ទះ, ការស្វែងរករបរចិញ្ចឹមជីវិត, ការអប់រំ និងអ្វីៗច្រើនទៀត មិនបានរៀបរាប់។ ស្ទើរតែនៅគ្រប់ពេល មាតាគឺជាអ្នកធ្វើការបោកគក់ ឬការងារចង្ក្រានជើងឆ្នាំង។ ដូច្នេះ ខ្ញុំសូមនិយាយចំអកឡើងថា "អ្នកជាកូនមិនដឹងអ្វីទេ! អ្នកមិនដឹងថា តើធ្វើយ៉ាងណាឱ្យមានសេចក្តីអាណិតអាសូរចំពោះស្ត្រីជរាទេឬ?។ ឬអ្នកមិនដឹងថា តើធ្វើយ៉ាងណាដើម្បីជួយនាងទេ?។ អ្វីដែលខ្ញុំចង់និយាយ គឺថា ពួកគេរស់នៅយ៉ាងរំភើយណាស់ ខណៈដែលពួកគេគួរណាស់តែជួយមាតាភ្លាមៗ។ នៅពេលខ្ញុំនិយាយបញ្ហានេះ ម្តងហើយម្តងទៀត ពួកគេហាក់បីដូចជាមិនមានឥទ្ធិពលលើឡើយ។ ប៉ុន្តែ មាតាដ៏កំសត់! នៅពេលខ្ញុំនិយាយសំដៅនាងថា "ស្ត្រីជរា" ជាក់ស្តែង នាងចាស់មែនទែន និងក្រៀមក្រំចិត្តទៀត។

Then, another way of my admonition. At home family members have a lot of engagements--

household chores, livelihoods, education, and what not. Mostly Mother is doing the wash, or in the kitchen. So I blurt out, “You unknowing children! Don’t you know how to have sympathy for the old woman? Or to help her?” What I mean is: They live lightly, while they should help Mother immediately. When I say this again and again they seem to remain unaffected. But, the poor Mother! When I refer to her as ‘old woman’ she gets virtually older, and depressed.

ទាំងនេះបានធ្វើឱ្យមានការពិចារណាឡើងវិញ នូវវិធីទូន្មានរបស់ខ្ញុំ ហើយខ្ញុំមានអារម្មណ៍ថា រឿងនេះមិនគួរគប្បីដោះស្រាយតែម្នាក់ឯងឡើយ ជាមួយនឹងចំណេះដឹង និងដួងចិត្តនៃបុគ្គលម្នាក់។ ប៉ុន្តែ ជាង ៤, ៥, ១០ ឆ្នាំកន្លងមកនេះ មាតាបិតា និងកូនបានស្តាប់ធម្មទេសនារបស់ព្រះតេជគុណ និងកាសែតជាច្រើន ដើម្បីជាប្រយោជន៍ដល់ក្រុមទាំងសងខាង។

These led to reconsideration of my way of admonition, and I felt it should not be handled alone, with the knowledge and mentality of one person. But over the past 4-5-10 years parents and children have been listening to Venerable’s discourses, and some taped ones, to the benefit of both groups.

ដូច្នេះ តើយើងត្រូវផ្សារភ្ជាប់ខ្លួនពួកយើងដោយរបៀបណា? វាគឺថា "ខ្ញុំគឺខ្លួនខ្ញុំ មិនមែនគាត់ ឬនាងទេ"។ និន្នាការនៃការគិតនេះនាំឱ្យមានការកាត់បន្ថយនូវភាពតានតឹងនៅឯផ្ទះ។ ដោយមិនចាំបាច់សម្រក់ទឹកភ្នែក សមាជិកគ្រួសារគួររស់នៅប្រកបតែសេចក្តីសុខម្នាក់ៗត្រូវដឹងនូវទំនួលខុសត្រូវរបស់គាត់ ឬនាង។ ចប់តែប៉ុណ្ណេះឯង។

So, how to mend ourselves? It is: I am I, not him or her. This trend of thinking leads to lessening of tension at home. Without cause for shedding tears, household members would go on living happily, each with awareness of his/her responsibilities. That’s all.

កញ្ញា **ម៉ា នី អ៊ូន ឡាំង** (Daw Ma Ni One Hlaing)

ជាធម្មតា ខ្ញុំចង់សម្រេចបំណងល្អបំផុត ដូចជាបងប្រុសដែរ។ ប៉ុន្តែ ការទូន្មានរបស់ពុក គឺសំដៅមកលើរូបខ្ញុំ ដែលជាកូនស្រីតែមួយគត់។ ជាក់ស្តែង ខ្ញុំជួយម៉ែដែរក្នុងការបោកគក់។ ជួនកាលមានសំលៀកបំពាក់ច្រើនពេក ជាពិសេសបងប្រុសស្លៀកមួយថ្ងៃបីបួនកំប្លេក៏មានដែរ។ ខ្ញុំមិនអាចធ្វើការបោកគក់ដ៏ច្រើនម្លឹងៗតែម្នាក់ឯងទេ ប៉ុន្តែ ពុកបានចាប់ផ្តើមជេរស្តីបន្ទោសខ្ញុំ។ ខ្ញុំប្រាប់ម៉ែ សូមឱ្យបង

ប្រុសជួយធ្វើការបោកគក់នេះផង។ ប៉ុន្តែ គាត់មិនស្តាប់ខ្ញុំទេ ហើយគាត់បោកគក់ខ្លួនឯង។ រឿងនេះកើតឡើងមួយលើកជាពីរលើក។ ពួកយើងជាកូនចៅប៉ុណ្ណោះ ដូចកាលដែលមាតានិងបិតានៅជាកូន-ចៅដែរ ហើយឥឡូវនេះ ពួកគាត់គឺជាមាតាបិតា។ ដូច្នេះ យើងសមនឹងមានពេលវេលាច្រើន ក្នុងការធ្វើឱ្យមានគំនិតចាស់ទុំ។

Naturally, we want to achieve the best and just so for Elder Brothers. But Father's admonition is mainly aimed at me, the only daughter. For example, I help Mother in the washing. Sometimes there is a large wash, mainly because Brother uses three or four sets of fresh wash even in a day. I cannot do a large wash all alone, yet Father begins scolding me. I tell Mother to make Brothers share doing the wash. But she will not listen, and does it herself. This happens time after time. We are offspring only, while Father and Mother were once offspring and are now parents. So we deserve more time in maturing.

លោក **ភូ អោង ប្យូ ទុន** (U Ko Aung Phyo Htun)

ខ្ញុំយល់ស្របនឹងអ្វីដែលពូទើបតែនិយាយអម្បាញ់មិញ ចំពោះឥទ្ធិពល ដែលមាតាបិតា និងកូន គឺជាបុគ្គលស្រឡាញ់គ្នាទៅវិញទៅមក។ ប៉ុន្តែ ខ្ញុំនៅតែមិនយល់សោះថា តើហេតុអ្វី ទើបការយល់ខុសចាប់ផ្តើមកើតឡើងរវាងពួកគេគ្រប់ពេលវេលាអ៊ីចឹង? ។

I agree with what uncle just said, to the effect that Parents and Children are beloved of one another. But I cannot still understand why misunderstandings begin developing between them over time.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

ពីជំនាន់មួយទៅជំនាន់មួយ យើងជាចៅអធិការមិនមែនព្យា-យាម ដើម្បីទទួលនូវការគោរព និងការឱនលំទោនច្រើនប៉ុណ្ណោះទេ។ សីល សមាធិ និងបញ្ញា គឺអាស្រ័យលើបុគ្គលម្នាក់ៗ។ យោង-ទៅតាមព្រះមហាថេរៈ អ្នកទ្រទ្រង់នូវធម៌របស់យើង វាសំខាន់ណាស់ ក្នុងការទទួលបាននូវសេចក្តីគោរពពីបុគ្គលដែលនៅកៀករូបអ្នក ជាជាងពីបុគ្គលដែលនៅឆ្ងាយពីអ្នក ហើយជាថ្មីម្តងទៀត វាប្រសើរណាស់ ក្នុងការគោរពខ្លួនឯង ជាជាងពីបុគ្គលដែលនៅកៀកអ្នក។ អ្នកខាងក្រៅមិនដឹងពីភាពទន់ខ្សោយរបស់អ្នកទេ ប៉ុន្តែអ្នកនៅកៀកអ្នកដឹងច្បាស់ណាស់។ អ្នកដែលរស់នៅក្រោមដំបូលតែមួយ កត់សម្គាល់នូវភាពទន់ខ្សោយគ្នាទៅវិញទៅមកច្រើន។

We abbots, one generation after another, are not trying to get more respect, mote adoration only. Morality, concentration and wisdom are the concern of an individual. According to our Dhamma-bearer Mahathera, it is important to win respect from those near you rather than from those far away, and again, it is better to have self-respect rather than respect from those near you. Outside persons are not aware of your weakness, but those near you are. Those living under one roof notice one another's weakness more.

ប៉ុន្តែ ដូចជានៅពេលមួយខ្ញុំបាននិយាយថា មានផ្លូវពីរយ៉ាងក្នុងការកត់សម្គាល់បែបនេះ គឺៈ ស្វែងរកចាប់កំហុសសម្រាប់ស្ដីបន្ទោស និងស្វែងរកភាពទន់ខ្សោយសម្រាប់អត់ធន់។ ប្រសិនបើ មេត្តាធម៌ពិតមាន សូម្បីតែភាពទន់ខ្សោយរបស់បិតា ឬមាតា បុគ្គលណាមួយគួរគប្បីចង្អុលបង្ហាញដោយស្វាត់ៗ។ ហើយបានបំពេញបង្គ្រប់ដោយការផ្ដល់នូវយោបល់សម្រាប់ការតភ្ជាប់។ ប៉ុន្តែ ប្រហែលជា ដោយ-សារការរសាត់ប៉ើងបាត់នៃមេត្តាធម៌នៅក្នុងគ្រួសារ ទើបបានជាការស្វែងរកចាប់កំហុសសម្រាប់ជេរស្ដីបន្ទោស កាន់តែកើនខ្លាំងជាងការផ្ដល់យោបល់សម្រាប់ផ្សារភ្ជាប់ទៅវិញ។

But as I once said, there are two ways to such noticing--namely, to find fault for blaming and to find weakness for remaining. Whatever, if true *mettā* or loving kindness exists, even Father's or Mother's weakness, if any, should be pointed out by the rest. And complemented with suggestions for mending. But, maybe due to fading away of loving-kindness in a family, finding faults for blame is getting stronger than making suggestions for mending.

សមាជិកគ្រួសារទាំងអស់ជាមនុស្ស ហើយប្រហែលជាងាយនឹងធ្វើខុស។ ក្នុងទីនេះ មាតាបិតាទាំងឡាយបាននិយាយចេញឡើងពីទស្សនវិស័យនៃបុកពា និងការប្រតិបត្តិរបស់ពួកគេ។ ដើម្បីធ្វើឱ្យកូនមានអាកប្បកិរិយាល្អ មាតាបិតាត្រូវការផ្សារភ្ជាប់នូវទម្លាប់របស់ពួកគេ។ ទម្លាប់នេះមិនអាចសម្លាប់ទេ ប៉ុន្តែត្រូវផ្សារភ្ជាប់។ ហើយអ្នកត្រូវតែផ្សារភ្ជាប់។ ឥឡូវនេះ ដើម្បីឆ្លើយតបសម្ដីរបស់កូនប្រុស ដែលទើបតែនិយាយអម្បាញ់មិញ ពោលគឺបញ្ហារបស់អ្នកកើតមានឡើង ព្រោះតែការស្វែងរកចាប់កំហុសអ្នកដទៃ ដើម្បីស្ដីបន្ទោស មិនអីចឹងឬ? ប៉ុន្តែ បើអ្នកជាមនុស្សឆ្លាតជាងអ្នកដទៃ ការស្វែងរកភាពទន់ខ្សោយរបស់អ្នកទៃ ហើយផ្ដល់នូវយោបល់សម្រាប់ការផ្សារភ្ជាប់ គឺល្អបំផុត។ គ្មានបញ្ហាអ្វីកើតឡើងបានឡើយ។

Family members are only human--and likely to err. Parents here just spoke up, from the perspective of their outlook and practice. To have the children well-behaved, Parents need to mend their bent. Bent may not be killed but be mended.

And mend you must. Now, to answer Son's speech just made--your problem cropped up for finding fault of others to blame, isn't it so? But, as one intelligent person to another, to find other's weaknesses and make suggestions for mending is the best. No problem would arise.

ទម្លាប់ និងការប្រតិបត្តិរបស់ព្រះសង្ឃគឺផ្សេងពីគ្នា។ យើងបានផ្សារភ្ជាប់នូវមាគ៌ារបស់យើងតាមលំដាប់ ដោយអាស្រ័យលើពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ និងគ្រូទាំងឡាយផ្សេងទៀត។ ខ្ញុំគ្មានភាពលំអៀងចំពោះកូនៗណាទេ។ ខ្ញុំត្រូវតែរំលឹករឿងនេះ ជារឿយៗ ចំពោះអត្តទោសរបស់ខ្ញុំ។ មាតាបិតាតែងតែរក្សាទឹកមុខសប្បាយរីករាយ នៅពេលជជែកវែកញែកជាមួយអ្នកដទៃ ប៉ុន្តែពួកគេរក្សាទឹកមុខមាំ នៅពេលជួបមុខកូនរបស់គេ។ តើនឹងឬសម្រាប់ធ្វើឱ្យកូនមានអាកប្បកិរិយាល្អ?។ តើនឹងឬជាទម្លាប់ដែលមិនផ្សារភ្ជាប់ឪពុកម្ដាយ?។ អាកប្បកិរិយារបស់ពុកម៉ែនេះមិនត្រឹមត្រូវទេ ហើយពួកគេត្រូវតែផ្សារភ្ជាប់ឱ្យទាល់តែបាន។

A monk's bent and practice are different. We have gradually mended our ways, relying on the admonition of Lord Buddha and other teachers. I have no bias in favour of Children. I have had to remind this often to my inconvenience. Parents tend to keep a happy countenance when dealing with their friends, but they keep a stern countenance when facing their children. Is this for making Children well-behaved? Is this Parents' unmended habit? This behaviour of Parents is wrong and must be mended without fail.

បន្ទាប់មក កូនរបស់អ្នកនឹងរីកចម្រើន និងធ្វើអាកប្បកិរិយាទៅតាមសេចក្ដីប្រាថ្នារបស់អ្នក។ រឿងនេះអាស្រ័យខាងផ្នែកពុក-ម៉ែ។ កូន! តើអ្វីជាភាពរឹងមាំរបស់អ្នក ក្នុងភាពកក់ក្ដៅរបស់ពុកម៉ែរបស់អ្នក ហើយតើពួកគេមានអារម្មណ៍យ៉ាងណា?។ ចំពោះខ្លួនខ្ញុំ ខ្ញុំមិនចង់ផ្អិផ្អាល់ខ្លួនខ្ញុំទាក់ទងនឹងអាកប្បកិរិយារបស់ខ្ញុំ។ ក្នុងនាមជាកូនច្បងម្នាក់ ខ្ញុំបានបោកគក់សំលៀកបំពាក់របស់មាតា រួមទាំងសំពត់។ ជួនកាល ខ្ញុំចំអិនអាហារសម្រាប់គ្រួសារទាំងមូល រៀបតុអាហារពេលល្ងាច និងលាងចានទាំងអស់តែម្នាក់ឯង។ ខ្ញុំដឹងការងារផ្ទះទាំងនេះ ធ្វើឱ្យល្អ ដឹងខ្លួនឯង ទម្លាប់ល្អ។

Only then will your children improve and behave in accord with your wishes. This is concerned with the side of Parents. Children! What are your strengths in your parents' favour and how do they feel about it? I, for one, do not want to blow my own trumpet concerning my behaviour. As eldest one, I did washing of Mother's dresses including nether garments. Sometimes I cooked for the whole household, set the dinner table and did the dishes all alone. I

knew these chores to be good, self-satisfying, a good habit.

ឥឡូវ ក្នុងសម័យកាលនេះ ទម្លាប់ប្រភេទនេះក្រណាស់ ទោះបីមិនបាត់អស់ក៏ដោយ។ មាតាបិតាសង្ឃឹមនូវអាកប្បកិរិយារបស់កូនបែបនឹង តើពួកគេបំពេញដែរឬទេ?។ បន្ទាប់ពីដើរលេងទៅក្រៅជាមួយមិត្ត សប្បាយរីករាយ ចរិតរីករាយ កូនៗមិនគួរធ្វើទឹកមុខក្រញ៉ៀក្រញ៉ូវ នៅពេលវិលត្រឡប់មកផ្ទះវិញ។ អាកប្បកិរិយាបែបនេះគឺត្រូវផ្សារភ្ជាប់។ នេះ គឺការដឹងនូវភាពទន់ខ្សោយ ដោយក្រុមនីមួយៗ ពុកម៉ែ និងកូន។ តាមតថភាពពិត អាកប្បកិរិយាបុគ្គលម្នាក់ៗអាចត្រូវផ្សារភ្ជាប់បាន។

Now, in this era, this kind of habit is rare, if not extinct. If Parents expected so-and-so behaviour of Children, could they oblige? After going out with friends in a happy, joyous manner, Children should not keep a sullen face when back at home. This behaviour is to be mended. This is knowing own weakness by each group, Parents or Children. In reality, one's bent or behaviour can be mended.

ដើម្បីឱ្យមានគ្រួសារប្រកបដោយសេចក្ដីសប្បាយ សុភមង្គលនោះ ត្រូវផ្លាស់ប្ដូរទម្លាប់ និងការអនុវត្តរបស់ខ្លួន។ រឿងនេះត្រឹម-ត្រូវចំពោះកូនទាំងអស់ ក៏ដូចមាតាបិតាដែរ។ ប្រសិនបើ ពួកគេបានផ្លាស់ប្ដូរតាមដែលចាំបាច់ ក្រុមនីមួយៗច្បាស់ជាដឹងនូវភាពទន់-ខ្សោយរបស់អ្នកដទៃ ហើយជួយពួកគេដោយវិធីផ្ដល់យោបល់។ មានតែការផ្សារភ្ជាប់តូចតាចប៉ុណ្ណោះ ត្រូវការធ្វើឱ្យបាន ហើយគ្មានហេតុផលណា ដែលមិនទទួលយកវានោះឡើយ។

To really have a happy, peaceful family means to change one's bent and practice. This holds true for Children as well as Parents. If they changed as necessary, each group would discern the other's weaknesses and help them by way of suggestions. Only some small mending needs to be made, and there is no reason for not undertaking it.

## ផ្នែកទី ៥
## Part V

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

តើកម្មវិធីនេះសម្រាប់អ្វីទៅ? មនុស្សលោកគឺពោរពេញដោយបញ្ហា និងភាពលំបាក។ ដើម្បីយកជ័យជំនះលើបញ្ហាទាំងអស់នេះ អ្នកត្រូវមានចំណេះដឹងច្រើន។ នេះគឺជាហេតុផល។ អ្នកគ្រប់រូបនៅទីនេះមានអារម្មណ៍ ហើយមនុស្សដទៃទៀតក៏អ៊ីចឹងដែរ។ យើងចង់ធ្វើទីវាលនេះឱ្យរាបស្មើ តាមលទ្ធភាពដែលអាចធ្វើបាន ប្រសិន-

បើ មិនអាចបានឥតខ្ចោះទេនោះ។ ប្រសិនបើ មានឧបសគ្គណាមួយក្នុងការទំនាក់ទំនង អ្នកទាំងអស់គ្នាអាចព្យាយាមឈ្វេងយល់គ្នា។ ឥឡូវនេះ សូមកូននិយាយមុន។

What is this programme for? The Human world is full of trouble and difficulties. To overcome them, we need more knowledge. That is the reason. Every one of you here has feelings, and so do the other person. We want to level the field as much as possible, if not perfectly. If there are any obstacles in relationship, you all try to have understanding. Now Children may speak first.

លោក **ម៉ាឃ្ម យ៉េ សាយ ឡាត** (U Mg Ye Zay Latt)

ខ្ញុំមានជំនឿថា ខ្ញុំមិនមែនជាក្មេងប្រុសដែលមានការអប់រំល្អទេ។ ខ្ញុំក៏មិនមែនជាក្មេងប្រព្រឹត្តល្មើសដែរ។ ក្នុងការបង្រៀន និងអប់រំពួកយើង អាយុកាល និងភាពចាស់ទុំនៃចំណេះដឹងរបស់យើងនេះ ត្រូវការគិតពិចារណា ដើម្បីឱ្យពួកយើងអាចយល់នូវការអប់រំដែលផ្ដល់ឱ្យនោះ។ ជាឧទាហរណ៍ ពេលយើងនៅពីក្មេងខ្ចី យើងតែងខ្លាចមិនហ៊ានទៅកន្លែងនេះ ឬកន្លែងនោះទេ ព្រោះគេនិយាយថាកន្លែងនោះ មានខ្មោចលង។ ឬបានរំលឹកថា អាចជាកន្លែងគ្រោះថ្នាក់ ដោយសត្វឆ្កែធំៗខាំ ឬកាត់ក្បាលដោយមនុស្សឃាតករ។

I believe I am not a model cultured boy. Nor am I a delinquent. To teach and train us, our age level and maturity of knowledge need to be considered so that we might understand the training being given us. For example, when we were quite young, we were often frightened not to go here or there because those places were said to be haunted. Or reminded of the possible danger of being bitten by a large hound or being decapitated by a murderous person.

ពាក្យទូន្មានប្រភេទនេះ បានកប់នៅជាប់ជាមួយពួកយើងយ៉ាងជ្រៅ។ ការស្រឡាញ់សម្រាប់ប្រយោជន៍កូនប្រុសស្រី និងសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួន ទោះជាយ៉ាងណាមានលក្ខណៈផ្សេងគ្នា ពោលគឺមានការបម្រើខ្លួនបន្តិច។ ខ្ញុំចង់គិតថា ការចិញ្ចឹមកូនដោយមេត្តាធម៌គឺ ប្រសើរជាង។ ឧបមាថា ក្មេងប្រុសឆ្លាតបានបញ្ចប់ថ្នាក់ ដោយមានពិន្ទុគ្រប់គ្រាន់ សម្រាប់ចូលរៀនវិទ្យាស្ថានវេជ្ជសាស្ត្រ។ ប៉ុន្តែថាគាត់ចង់ចាប់យកមុខជំនាញប្រវត្តិវិទ្យា។

This sort of admonition stayed with us very deeply. Loving for sons and daughters' sake and for one's own sake are somewhat different--the latter is a bit self-serving. I would like to think:

Bringing up children with loving-kindness is better. Suppose a clever, well-bred boy has matriculated, with enough marks for admission into a medical institute. Suppose again that he wants to major in History.

មុខវិជ្ជានេះ មាតាបិតារបស់គាត់មិនទទួលស្គាល់។ នេះ ក្មេងចង់ចាប់យកការសិក្សាតាមការពេញចិត្តរបស់គាត់ ដែលមាតាបិតាបដិសេធ។ ប្រសិនបើ ក្មេងនេះមានមានៈ តើត្រូវចាត់ទុកគាត់ជាមនុស្សប្រភេទណា? ។ ក្មេងពាល? ។ ក្មេងល្ងើយ? ។ ឬក្មេងឆ្លាត? ។ តើអ្វីទៅជាកម្រិតដែលមាតាបិតាគិតឱ្យកូនឆ្លាត? ។ រវាងពួកគេបញ្ហាប្រភេទនេះ គឺមិនអាចចរចាបានឡើយ។ កូនៗសមនឹងទទួលបាននូវជំនឿខ្លះក្នុងពួកគេ។ ដោយភាពជឿជាក់ មាតាបិតាអាចលើកកំពស់កូនរបស់គេ ដោយមិនចាំបាច់សេចក្តីស្រឡាញ់ហួសប្រមាណនោះទេ។ ពួកគេអាចណែនាំកូនដោយមានហេតុផល ជាមួយនឹងពាក្យផ្អែមល្ហែម។

This his parents will not accept. Here a child likes to take up studies in accord with his bent, which his parents reject. If this child persists, how would he be judged? A fool? A delinquent? Or a clever boy? What are the standards by which Parents judge Children to be clever? Between them these sorts of problems are non-negotiable. Children deserve some faith in them. With faith

Parents may raise their children without excessive pampering. They could bring children to reason with sweet words.

ប្រសិបើ ធ្វើដូច្នេះបាន កូនមិនអាចបរាជ័យក្នុងជីវិតឡើយ។ តាមពិតទៅ ខ្ញុំជឿជាក់អ៊ីចឹងឯង។ យុវជនទាំងឡាយតែងតែអប់រំកូនរបស់គេ តាមបទពិសោធន៍ជីវិតរបស់គេនៅក្នុងចិត្ត។ ប៉ុន្តែ បទពិសោធន៍ទាំងនេះមិនមែនជាបទពិសោធន៍អ្នកទេ។ បទពិសោធន៍របស់អ្នកទាំងពីរផ្នែកមិនអាចដូចគ្នា ឬដូចគ្នាសុទ្ធសាធឡើយ។ នៅពេលណា យើងត្រូវការចាំបាច់ យើងឱ្យមាតាបិតានៅក្បែរយើងទំនុកបម្រុងយើងពេលណាសំខាន់។ ពេលយើងអាចរៀបចំខ្លួនឯងបាន ពួកគេក៏គួរតែនៅខ្វល់ខ្វាយស្រឡាញ់ពេញបេះដូង។ នោះគ្មានបញ្ហាអ្វីនឹងកើតឡើងទេ។ អរគុណច្រើនព្រះតេជគុណ។ អរគុណអ្នកទាំងអស់គ្នា។

If so, Children could not fail in life. Indeed, I believe this. Adults always admonish their Children with their life experiences at the back of their mind. But those experiences are not ours! The two sides' experiences cannot be alike, or identical. When we are needy, we want parents standing besides us, supporting us whenever necessary. When we are sort of able to manage ourselves they should still be caring loving to the

full. Then no trouble will not arise. Thank you, Venerable Sir. Thanks to all of you.

អ្នកស្រី **ឃីន ថាន តាយ** (Daw Khin Than Htay)

ព្រះតេជគុណ! ខ្ញុំនឹងមិននៅបានយូរទេ។ ព្រះសម្មាសម្ពុទ្ធបានសម្តែងអំពីសង្គហធម៌ប្រាំប្រការ។ តើមានន័យដូចម្តេចទៅ ពាក្យមួយឃ្លាថា "មាតា និងបិតាគឺជាគ្រូដើម"?។ ហើយចំពោះបញ្ហានេះដែរ ពាក្យមួយឃ្លាទៀតនិយាយថា "ល្អី និងចានឆ្នាំបែកបាក់ត្រូវគេបោះចោល ប៉ុន្តែ កូនអាក្រក់វិញ មាតាបិតាមិនដែលបោះបង់ចោលឡើយ"។ មាតាបិតាស្រឡាញ់កូនគ្មានព្រំដែនទេ។ កូនច្រើនតែមើលមាតាបិតារបស់គេយ៉ាងលំបាក ប៉ុន្តែ មាតាបិតាតែងតែធ្វើនូវកិច្ចការនោះ។ ខ្ញុំចង់ដេក ប៉ុន្តែ នៅពេលកូនប្រុសឈឺ ខ្ញុំមិនអាចដេកកើតឡើយ ខណៈបិតារបស់គាត់ងងុយដេក។ ខ្ញុំឆ្ងល់ថា នៅពេលមាតាបិតាឈឺ តើមានកូនណាមើលថែទាំពួកគាត់ដែរទេ?។

Venerable Sir, I will not be long. The Buddha included Parents in the Five Great Benefactors. What to say of the saying: Father and Mother are the first-ever teachers? And, for that matter, the saying: Broken baskets and containers are thrown away, but ill-bred children are never cast off. Parents love for children is limitless. Children hardly watch over their parents, but parents are always doing that. I love sleeping, but when my son is sick I cannot sleep while his father might be asleep. I wonder: when parents are sick, are there any Children watching over them?

អ្វីដែលកូនប្រុសទើបតែនិយាយអម្បាញ់មិញ ទាក់ទងទៅនឹងទម្លាប់របស់គាត់ វាប្រហែលជាត្រឹមត្រូវ។ ប៉ុន្តែ ក្នុងនាមខ្ញុំជាមាតាម្នាក់ ខ្ញុំមិនចាត់ទុកទស្សនៈគាត់ថា ត្រឹមត្រូវទេ។ ពេលមួយខ្ញុំនៅផ្នែកខាងកូនៗ ប៉ុន្តែ ឥឡូវនេះ ខ្ញុំនៅខាងផ្នែកមាតាបិតាម្តង។ គោលបំណងរបស់យើងចំពោះកូនៗ ច្បាស់ជាមកពីអត្តៈមែនហើយ ប៉ុន្តែ ការលោភលន់របស់យើង មិនមែនសម្រាប់ប្រយោជន៍របស់យើងទេ ប៉ុន្តែភាពជោគជ័យរបស់កូននៅក្នុងជីវិតនេះ។ ដូចជាពាក្យស្លោកភូមាមួយថា "ទឹកនៅក្នុងអូរ ហូរចុះបណ្តោយខ្សែទឹកប៉ុណ្ណោះ មិនដែលហូរបញ្ច្រាសខ្សែទឹកឡើយ"។ កូនអាចធ្វើទុកក្នុងចិត្តបាននោះពួកគេនឹងទទួលផ្លែផ្កា។ ខ្ញុំមិនដែលគិតថា "ខ្ញុំនឹងរស់នៅដោយសារកូន នៅពេលពួកបានជោគជ័យក្នុងជីវិត" ទេ។ ខ្ញុំមានជំនឿថា ទឹកចិត្តនេះ គឺធម្មតាចំពោះមាតាបិតាគ្រប់រូប។

What a Son just said-concerning his bent--it probably is true. But, as a parent I do not hold his views as true. I once was on Children's side, but I am now on Parents' side. Our intention towards Children may have come from our *atta* of Self, but our greed not for our sake but for that of

Children's success in life. As a Myanmar saying goes: Water in a stream only flows downstream, never upstream. Children might make it in life, and they can enjoy the fruit. I never think: I would be able to live depending on Children when they become successful in life. This mentality is common to all Parents, I believe.

អ្នកស្រីវេជ្ជបណ្ឌិត **ប្យូ ប្យូ អូ** (Dr. Daw Phyu Phyu Oo)

ខ្ញុំជាម្ដាយមួយរូប។ អ្វីដែលកូនប្រុស កូនស្រីបាននិយាយមកនេះ ប៉ះទង្គិចខ្ញុំច្រើនណាស់។ ដូច្នេះ ខ្ញុំសូមឆ្លើយតបខាងផ្នែកមាតាបិតា។ ដំបូងសម្ដីកូនប្រុសទើបនិយាយឡើង។ វាជាសម្ដីដែលអាចទទួលយកបានចំពោះខ្ញុំ ព្រោះតាមបទពិសោធន៍របស់ខ្ញុំ។ តើព្រោះហេតុអ្វី? ។ មាតាបិតាមួយចំនួនកំណត់នូវមុខវិជ្ជាសម្រាប់កូន ដោយមិនបានពិចារណាថា តើកូនអាចចាប់យកបានឬអត់។ ក្បាលរបស់គាត់ ឬ នាងបានស្លុគស្មាញនឹងការងារសាលា កូនខ្លះក្លាយទៅជាឆ្កួត។ សម្រាប់កូនដទៃទៀត ពួកគេក្លាយជាមានមោទនភាពខ្លាំងក្លាជានិស្សិតពេទ្យ។ ដោយជឿថា ភារៈកិច្ចរបស់ពួកគេត្រូវបានគេធ្វើឱ្យ ពួកគេមិនមានអារម្មណ៍រៀនសូត្រឡើយ។

I am a parent. What Sons and Daughters said impacted me a lot. So did the replies of Parents. First, the Son's speech just made. It is entirely acceptable to me because of my own experience. Why? Some Parents dictate the course of things for Children, without considering whether the child is able to cope with them. His/Her head is packed tight with schoolwork, some even going insane. For some others, they become over-proud as medical students. Believing their duty is done, they do not feel like studying any more.

ម៉្យាងវិញទៀត ប្រហែលជាការអស់កម្លាំងចិត្តនេះ ត្រូវតែទទួលខុសត្រូវ។ ប្រសិនបើមិនដូច្នេះទេ កូនអាចមានអារម្មណ៍ថា គោលដៅដែលមាតាបិតាដាក់ឱ្យត្រូវតែបំពេញ ហើយមួយណា គឺមួយហ្នឹង។ មួយវិញទៀត មាតាខ្លះជូនកូនរបស់នាងទៅសាលា។ មាតាបិតានៃគ្រួសារបែបនេះ តាមដានការអប់រំ បរិស្ថាន និងការរកស៊ីរបស់គ្រួសារ ហើយបន្តជួយថែរក្សាកូនទៀតផង។ ប្រសិនបើដូច្នេះ កូនគួរតែយល់ពីមាតាបិតាច្បាស់ ហើយអ្វីៗអាចប្រព្រឹត្តទៅយ៉ាងរលូន។ កូន! តើកូនមិនគិតថា មាតាបិតាកំពុងតែប្រជ្រៀតអ្នកទេឬ នៅពេលណាអ្នកមានអារម្មណ៍អស់សង្ឃឹម? ។ នេះមិនមែនត្រឹមត្រូវទេ។ តាមធម្មតា ក្នុងនាមខ្លួនខ្ញុំជាមាតាម្នាក់ ខ្ញុំស្រឡាញ់កូនប្រុសខ្ញុំ។

Again, perhaps exhaustion could be responsible. If not, the child might feel the objective set by his parents is accomplished and that is that.

Another way--some Mother accompanies her child in studies. Parents of such a family overviews education matters, environment and family's business and go on to help the child with care. If so, the child would understand Parents well and things might run smooth, I think. Children, don't you think that Parents are bullying you whenever you feel disappointed? This is not true. Being a mother myself, I love the son, naturally.

ក្នុងនាមជាមាតាធ្វើការងារ ខ្ញុំចាកចេញពីផ្ទះតាំងព្រឹកព្រលឹម។ កូនប្រុសរបស់ខ្ញុំ គឺខុសប្រក្រតី ចាប់តាំងពីគាត់បាត់បង់ច្រើនទៅ។ ប្អូនប្រុសរបស់គាត់បានស្លាប់តាំងពីទារកភាព។ ប៉ុន្តែ យើងយល់ថា គាត់ប្រព្រឹត្តតាមយ៉ាងល្អ។ តាងនាមឱ្យមាតាធ្វើការងារ ខ្ញុំចង់និ-យាយថា យើងកំពុងធ្វើការងារសម្រាប់ការចំណាយរបស់កូនប្រុស ការសិក្សារបស់គាត់។ ការងារនេះបន្តរហូត ពីព្រោះកាលៈទេសៈអនុញ្ញាតឱ្យ។ ប្រសិនបើ អ៊ីចឹងទេ ខ្ញុំប្រហែលជាត្រូវបក់ឱ្យកូនប្រុសនៅតុអាហារពេលល្ងាច ពេលគាត់អាចរកចំណូលសម្រាប់គ្រួសារ។ ដូច្នេះ ការងាររបស់យើងមានន័យថា សម្រាប់សាធារណជនផង សម្រាប់ខ្លួនឯងផង សម្រាប់កូនៗផង សម្រាប់ប្រទេសទាំងមូលផង និងសម្រាប់ប្រជាជនទាំងអស់ផង។ យើងកំពុងតែធ្វើការសម្រាប់អ្នកទាំងអស់គ្នា ក៏ដូចជាសម្រាប់ខ្លួនយើងផងដែរ។ កូនៗច្បាស់ជាយល់ពីបញ្ហានេះ ហើយមាតាបិតាក៏អ៊ីចឹងដែរ។

Being a working mother, I leave home early in the morning. My son is somewhat exceptional since he has lost much. His younger brother died in infancy. Yet we find him adapting well. On behalf of working mothers I would like to say we are working for Son's expenditures, his education. This goes on because circumstances permit. If not, I would like probably be fanning the son at the dinner table, when he is maybe earning the bread for the family. So, our working means for the public as well as for self, for Children, country and all. We are working for all as well as oneself. Children might understand this, and Parents too.

កញ្ញា **ម៉ា ថា ស៊ីន វីន** (Daw Ma Tha Zin Win)

នៅពេលមាតាបិតា និងកូនមិននិយាយស្តីឡើង ហើយមាតាក៏មិនទប់កំហឹងរបស់នាងទៀត អ្វីៗប្រព្រឹត្តទៅអាក្រក់ក្នុងការដោះស្រាយជាមួយបិតា។ ខ្ញុំជាមនុស្សម្នាក់ដែលកំពុងតែនៅសិក្សា។ ហើយចំពោះការខិតខំខ្នះខ្នែងសម្រាប់ចូលរៀនជំនាញពេទ្យ។ ប៉ុន្តែពេលខ្ញុំរៀនថ្នាក់ទី១១ សុខភាពម្តាយរបស់ខ្ញុំខ្សោយទៅៗ។ ពេលយប់ខ្ញុំធ្លាប់គេចចេញទៅមក។ នេះគឺជាជម្រើសរវាងការសិក្សា

របស់ខ្ញុំ និងសុខភាពរបស់ម្ដាយ។ ពុកបានប្រាប់ខ្ញុំឱ្យឈប់ទៅរៀនទៀតទៅ។ ដោយសារតែការដុតបំផ្លាញនូវបំណងរបស់ខ្ញុំ ក្នុងការសិក្សាសម្រាប់ជំនាញវេជ្ជបណ្ឌិត ខ្ញុំបានឡើងសម្ពាធឈាមតាំងពីពេលនោះមក។

When parents and children do not speak up, and Mother does not suppress her dissatisfaction, things go bad in dealing with Father. I for one is given to pursuance of education. And to endeavours for entering the medical profession. But when I was in the 11th Grade, Mother's health went worse. By night she used to flee to and fro. Hence the choice between my education and Mother's health. Father told me to drop out of school. With my burning wish to train for doctorship, I developed high blood pleasure since then.

ទោះបីជាយ៉ាងណា ក្រោយពីស្ដាប់ធម្មទេសនា "កតញ្ញូកតវេទី" របស់ព្រះតេជគុណរួចមក ខ្ញុំបានដឹងថា មាតាបិតាច្បាស់ជាស្វែងរកនូវមេត្តាធម៌ពីប្រភពអ្វីក៏ដោយ ដែលគាត់ឬនាងអាចពឹងផ្អែកបាន។ ព្រះតេជគុណបានសម្ដែង ដូច្នេះសូម្បីតែជាកូន ប្រសិនបើ ខ្ញុំព្យាយាមចម្រើនមេត្តាធម៌ចំពោះមាតាបិតា បញ្ហាអាក្រក់ទាំងឡាយច្បាស់ជាឈប់កើតមានទៀតហើយ។ រឿងនេះបានបង្ហាញត្រូវណាស់ ក្នុងករណីរបស់ខ្ញុំ ដូចដែលខ្ញុំបានព្យាយាមឈ្វេងយល់ពីមាតាបិតាឱ្យបានច្រើន។ ខ្ញុំត្រូវតែធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីការពារមាតា។

However, after listening to Venerable's discourse "Reminder on Gratitude" I was enlightened that a parents might seek *mettā* from whatever source he/she can resort to. So, even as a child, if I tried to develop *metta* for parents worse things to come would be stopped, Venerable had discoursed. This proved true in my case, as I tried to be more understanding of parents. I had had to do everything to protect Mother.

ឥឡូវនេះ ខ្ញុំថែរក្សានាងដូចជាកូនក្មេងអ៊ីចឹង ដោយសារស្ថានភាពរបស់នាង។ ពេលណាបិតារងទុក្ខនូវរាងកាយ ខ្ញុំត្រូវតែចាត់ចែងការងាររកស៊ីទៀត។ ខ្ញុំបានរំលែកនូវអារម្មណ៍របស់បិតាខ្លះហើយ ទោះបីជាមិនបានទាំងស្រុង។ ខ្ញុំបានចាប់ដឹងថា ហេតុអ្វីបិតាមានភាពព្រងើយកន្តើយនឹងខ្ញុំ ព្រោះខ្វះពេលវេលា ពោលគឺគាត់បានរកស៊ីសម្រាប់ប្រយោជន៍គ្រួសារ។ ពេលខ្ញុំធ្វើការងារជំនួសមាតានូវកិច្ចការផ្ទះ ខ្ញុំបានចាប់ផ្ដើមចែករំលែកនូវអារម្មណ៍របស់មាតា ក្នុង

មុខងារនោះ។ ឥឡូវនេះ មាតាបិតាទាំងឡាយកំពុងច្បាប់ធម្មទេសនាទាំងនេះ។ សូមអរគុណ!

Now I am taking care of her like as child because of her condition. When Father suffered a stroke I had to step in to manage business affairs. I might have shared Father's feelings somewhat, if not completely. I began to learn why Father had sort of neglected me for a lack of time--he was steeped in business for the sake of the family! When I had to step in to take the place of Mother's regarding the livelihood of the family, I began to share Mother's feeling in that role. Now Parents are listening to these discourses. Thank you.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

ទស្សនវិស័យខាងកូនៗ ពួកគេអះអាងថា ខាងមាតាបិតាខ្វះភាពជឿជាក់លើពួកគេ។ ចំណែក ខាងទស្សនវិស័យរបស់មាតាបិតាក៏អ៊ីចឹងដែរ តើអ្វីជាព្រំដែនដែលកូនអាចបញ្ជាក់នូវគុណបំណាច់នៃសេចក្ដីស្មោះត្រង់របស់មាតាបិតា? នៅកម្រិត និងអាយុនីមួយៗនេះ តើកូនមានលទ្ធភាពដែលគួរឱ្យទុកចិត្តដែរទេ?។ ចូរវិភាគខ្លួនអ្នកចុះ។ សូម្បីតែចំណោមកូនៗខ្លួនឯង ក៏មិនអាចស្មើគ្នាផង។ សមត្ថភាពរបស់គេ គឺ មានតាំងពីកំណើត ហើយទាក់ទងនឹងសមត្ថភាពបុគ្គលម្នាក់ៗផងដែរ។ តាមធម្មជាតិ បុគ្គលខ្លះស្រឡាញ់តែខ្លួនឯង ហើយគេមិនអាចទុកចិត្តការងារពាណិជ្ជកម្ម ខាងដើមគំនិតផ្ទាល់របស់ខ្លួន។ វាគឺជារឿងធម្មតាប៉ុណ្ណោះ។

From Children's perspective, they claim the lack of faith in them on Parents' part. From Parents' perspective too, to what extent could Children prove to be worthy of their parents' trust? At each level and age, are Children possessed of trustworthy abilities? Analyse yourselves. Even among children individuals are not equal. Their qualities are innate, and are also concerned with individual capabilities. By nature some love solitude, and they cannot be trusted with conduct of business on their own initiative. It is only natural.

ត្រូវហើយ ចំពោះលទ្ធភាពតម្រូវការ តើសិស្សអនុវិទ្យាល័យអាចត្រូវបានគេគិតថា មានចិត្តគំនិតជាសិស្សអនុវិទ្យាល័យដែរទេ?។ នោះមានន័យថា តើគាត់ ឬនាងអាចថែរក្សាគ្រួសារទាំងមូលបានទេ?។ ជីវិតនៅសាកលវិទ្យាល័យ គឺនៅជាក្រុម។ តើគាត់ ឬនាងអាចជាជីវិតបក្ខពួកដែរទេ?។ កូន! អ្នកចង់បានជំនឿរបស់មាតាបិតាមកលើអ្នក ប៉ុន្តែ តើអ្នកមានលទ្ធភាពទាំងនោះដែរទេ?។ ប្រសិនបើ អ្នកមិនមានទេ មាតាបិតានឹងមិនមានជំនឿលើអ្នកទេ។ ជំនឿគឺត្រូវមានទៅលើគ្នាទៅវិញទៅមកប៉ុណ្ណោះ។ ការនិយាយស្ដី

ដោយគំរោះគំរើយ ជាអ្នកដែលមានការអប់រំល្អ ចង់ឱ្យជំនឿរបស់មាតាបិតាទៅលើអ្នក។ តើអ្នកប្រើការស្ទាបស្ទង់ដល់កម្រិតណាដែរ? ។

Well, regarding acquired qualities could a collegian be relied upon to have collegian mentality? That means, roughly, can he/she take care of the whole household? Life at university is gregarious. Could he/she be the life of the party? Children, you want parents' faith in you, but are possessed of qualities worthy of that? If not, parents will not have faith in you. Faith is only mutual. Roughly speaking, being well-bred means parents' faith in you. What is the measure to be used?

យើងសូមនិយាយថា មានពីរប្រភេទ គឺ ជាអ្នកឆ្លាតនឹងភ្នែកសាធារណជន និងដំណើរការនៅក្នុងមាគ៌ាផ្ទាល់របស់អ្នក។ ចំណោមផ្លូវទាំងពីរនេះ តើមួយណាពិបាកជាង? ។ អ្នកប្រាកដជានឹងឆ្លើយថា វាគួរឱ្យធុញទ្រាន់ ហើយការធ្វើជាមនុស្សឆ្លាតនៅមុខសាធារណជនលំបាកជាង។ តើព្រោះហេតុអ្វី? ។ សាធារណជនមិនមែនដូចគ្នានឹងរូបអ្នកទេ។ ចូរគិតដោយប្រុងប្រយ័ត្ន។ តើការសេពគប់នឹងអ្នកដទៃមានន័យដូចម្ដេច? ។ សម្រាប់សុភវិនិច្ឆ័យជាទីគាប់ចិត្តនៃសាធារណជន ឬសម្រាប់ដំណើរការបែបបទខ្លួនរបស់អ្នក? ។ ចូរកុំឆ្លើយសើៗ ដូចជាថា "យើងសេពគប់ជាមួយបុគ្គលណាម្នាក់ ដែលមានទង្វើល្អចំពោះយើង ដែលជាអ្នកធ្វើខ្លួនគាត់ ឬនាងយ៉ាងល្អប្រពៃចំពោះយើង"។ ចូរជ្រើសរើសដៃគូ។

Let's say there are two kinds--being clever in public eye and being progressive in one's own way. Which is more difficult between the two? You will surely answer it is more tiresome and difficult to be clever in public eye. Why? The public is not the same as you. Think carefully. What does association with others mean? For favourable judgement of the public or for your own self-styled progress? Don't answer lightly, like, "We associate with anyone who has goodwill for us, who conduct himself or herself well towards us". Do choose your companions.

អ្នកគឺដូចនឹងអ្វីដែលអ្នកសេពគប់ជាមួយ អ្នកកែប្រែដល់ទៅ៩0ភាគរយ ពោលគឺ ទៅជាអ្នកប្រមឹក អ្នកលេងល្បែងបៀរ ឬក៏ជាជនអនាថាសង្គម។ មិត្តភក្តិរបស់អ្នកគួរតែលើកតម្កើងជំនឿរបស់មាតាបិតាលើរូបអ្នក។ ប៉ុន្តែ កូនសិស្សវិញ ក៏មិនត្រូវបានគេបង្រៀនឱ្យលើកដៃប្រណមនៅមុខព្រះសង្ឃ ឬឱនក្បាលគោរពពេលដើរនៅជិតរាមច្បងដែរ។ ប្រហែលជាលោកគ្រូ អ្នកគ្រូផ្ដល់នូវការអប់រំបែបហ្នឹងដល់សិស្សទាំងឡាយ ប៉ុន្តែ ចំពោះខ្លួនខ្ញុំ ខ្ញុំនឹងមិនអប់រំបែប

ហ្នឹងទេ។ តើព្រោះហេតុអ្វីទៅ? ។ ការបង្ខំអ្នកដទៃធ្វើអាការៈត្រឹមត្រូវ ចំពោះមុខសាធារណជនពិបាកជោគជ័យខ្លាំងណាស់។ តាមពិតក្មេងនឹងស្អប់វា នោះជាអ្វីដែលខ្ញុំមានជំនឿ។

You are what you associate with, correct up to 90 percent--be it a drunkard, card-player, or a social outcast. Your companions should foster faith of parents in you, and completely at that. Yet the pupils are not specifically instructed to raise joined palms before the Saṅgha, or to bow in moving about near the elderly. Perhaps gent or lady teachers might give such instructions to the pupils, but I myself will not. Why? Forcing others to behave for good appearance in the public eye can hardly be successful. In fact Children will hate it, that is what I believe.

និយាយពីអក្សរសាស្ត្រវិញ ប្រសិនបើ បុគ្គលណាមួយពិតជាគោរពស្រឡាញ់ត្រៃសរណគមន៏ បុគ្គលមិនអាចជួយទេ ប៉ុន្តែ ត្រូវវន្ទនាចំពោះពួកគេ។ ការគោរពស្រឡាញ់ពិត គឺជាគោលដៅ។ ប្រសិនបើ បុគ្គលណាមួយជាអ្នកធ្វើខ្លួនឱ្យមានអាកប្បកិរិយាល្អ វាមិនមែនជារឿងធំដុំទេ ក្នុងការមើលទៅល្អនៅមុខសាធារណជន។ ចំណេះដឹង និងអាកប្បកិរិយារបស់ខ្ញុំ គឺ "ការអភិវឌ្ឍខ្លួនឯងទោះបីជា ចំណេះដឹងខ្លួនឯងល្អបំផុតក៏ដោយ"។ ប្រសិនបើដូច្នេះកូនល្អប្រាកដជាថ្វាយបង្គំព្រះសង្ឃ នៅពេលគាត់ ឬនាងជួប។ កូនត្រូវកត់ចំណាំថា វាមិនមែនជាសីលធម៌ល្អប្រពៃទេ ក្នុងការធ្វើអ្វីដែលស្នើដោយមាតាបិតា។

To refer to literature--if one really adores the Tree Gems, one cannot help but pay obeisance to them. Real adoration is the point. If one is a self-cultivator of good behaviour, it is not a big deal to look good in the public eye. My knowledge, my outlook is: self-improvement though self-knowledge is the best. If so, a good child will surely pay obeisance to the saṅgha when he/she meets one. Children note that it is not good morality only to do what is asked of you by the parents.

ជាថ្មីម្តងទៀត មាតាបិតាត្រូវរំលឹកឡើងវិញថា ប្រសិនបើអ្នកមានទឹកចិត្តប្រព្រឹត្តតាមតែសេចក្តីប្រាថ្នារបស់អ្នកប៉ុណ្ណោះ នោះកូនរបស់អ្នកនឹងវិនាសហើយ។ កូនប្រហែលជានឹងធ្វើតាមសកម្ម-ភាពចាំបាច់ណា ពេលមាតាបិតាបានចង្អុលបង្ហាញដោយវាចា។ ប្រ-សិនបើ មិនដូច្នោះទេ ពួកគេនឹងមិនប្រតិបត្តិតាមឡើយ។ រឿងក៏អាក្រក់ តើអ្វីត្រូវកើតឡើង នៅពេលមាតាបិតាមិននៅ ឬស្លាប់អស់ទៅ? ។ ការគោរពជាពាក្យណែនាំដោយវាចាប៉ុណ្ណោះ មានន័យដូចគ្នានឹងពាក្យទូន្មាន ដែលនឹងត្រូវបោះចោល ពេលណាអវត្តមាន

របស់លោកគ្រូ។ កូនជាមនុស្សដែលមានវប្បធម៌ មានន័យថា ការអភិវឌ្ឍខ្លួនឯង ឆ្លងតាមវិជ្ជាផ្ទាល់ខ្លួន។ អ៊ីចឹងទេ មនុស្សពូជល្អមានកម្រិតគុណភាពផ្សេងគ្នា។ គ្មានកូនដែលមានការអប់រំល្អណាពីរនាក់ដូចគ្នានោះឡើយ ពួកគេនីមួយៗមានអាកប្បកិរិយាល្អតាមមាគ៌ាផ្ទាល់ខ្លួនរបស់គេ។

In turn, Parents be reminded that if you only emphasize compliance with your wishes, your children will go to ruin. Maybe Children will comply when a required action is verbally pointed out by Parents. If not, they will not comply. Worse, what would happen when Parents are absent or no more? Obeying only a verbal instruction means such instruction will be discarded in the instructor's absence. Children, being cultured really means self-improvement through self-knowledge. Then, good breeding has different categories of quality. No two well-bred children are alike; each is well-behaved in his/her own way.

កូន! ខ្ញុំនឹងមិននិយាយថា តើវិជ្ជាពិតប្រាកដណាមួយល្អបំផុតសម្រាប់ក្លាយជាមនុស្សដែលមានវប្បធម៌ទេ។ អ្នកគួរគប្បីឈ្វេង-យល់ថា វាជាការពេញចិត្ត ក្នុងការធ្វើអាកប្បកិរិយាដូចអ្នកដទៃតាមអនុភាព ក៏ដូចជាក្នុងការស្វែងរកការអភិវឌ្ឍខ្លួនឯង ឆ្លងតាមវិជ្ជាផ្ទាល់ខ្លួនផងដែរ។ ចូររក្សាចំណុចនេះទុកក្នុងចិត្ត ហើយអ្នកនឹងក្លាយជាកូនដែលមានការអប់រំល្អមិនខានឡើយ។

Children! I will not say which specific course is best for being cultured. You should understand that it is desirable to behave like others in the mainstream as well as to seek self-improvement through your own knowledge. Keep this in mind, and be well-bred.

## ផ្នែកទី៦
Part VI:

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

មាតាបិតាមានបំណងចិញ្ចឹមកូនរបស់គេឱ្យល្អ តាមចរិយាមារ-យាទ ដែលពួកគេចូលចិត្ត ដូចជាតាមអាកប្បកិរិយា និងទម្លាប់របស់គេ។ កើតជាមួយម្ដាយ និងបិតាបែបនេះ កូនជាច្រើនបែរជាមានចរិយាខ្លះ ខុសស្រឡះពីចរិយារបស់មាតាបិតា។ បែបនេះហើយភាពលំបាកកើតឡើងនៅក្នុងទំនាក់ទំនងរបស់គេ។ សូម្បីតែ ពេលមាតាបិតា និងកូនមានចរិយាស្រដៀងគ្នាក៏ដោយ ភាពលំបាកទំនាក់ទំនងកើតជាថ្មី ដោយសារកាលៈទេសៈ និងបរិស្ថានជុំវិញ។ ដូច្នេះពាក្យទូន្មានរបស់ខ្ញុំចំពោះអ្នកទាំងអស់គ្នា។

Parents mean to bring up their children well in the manner they like, in accord with their behaviour and their bent. Born of such a Mother and such a Father, many children come to have some character very different from their parents'. As such, difficulties appear in their relationship. Even when Parents and Children have similar character, relationship difficulties develop again because of the times and enivironment. So, my admonition to you all.

ជាឧទាហរណ៍ ខ្ញុំចូលចិត្តសត្វឆ្កែ មិនមែនដោយរោមស្រម៉ូវរបស់វា, ខ្លួនធំ ទាំងមិនមែនដោយសារសម្បុររវានោះដែរ។ អ៊ីចឹងតើព្រោះហេតុអ្វី?។ សត្វឆ្កែតែងតែតាមអ្នកឱ្យចំណីរបស់វា ម្ចាស់របស់វា។ វាដេកនៅសងខាងម្ចាស់វា សកម្មភាពបែបនេះប្រៀបបីដូចជាអ្នកការពារ។ ឥឡូវនេះ តើកូនប្រុស និងកូនស្រីថែរក្សាការ-ពារមាតាបិតារបស់គេទេ?។ តើពាក្យរបស់ខ្ញុំមិនត្រូវទេឬ?។ ត្រូវហើយ តើអ្នកណាត្រូវនិយាយ?។ សូមអញ្ជើញមក។

For example, I like a certain dog, not for its bushy hair, large body, nor for its colour. Then, why? A dog always follows its feeder, its master. It scampers around him, sort of acting as a protector. Now, do Sons and Daughters protect their Parents? Aren't my words true? Well, who's left to speak up? Go ahead.

អ្នកស្រី **អោម ម៉ា អេ** (Daw Omma Aye)

ព្រះតេជគុណ! មាតាបិតាទាំងពីររបស់ខ្ញុំនៅមានជីវិតទេ ប៉ុន្តែមិនអាចធ្វើការងារកើតឡើយ ព្រោះចាស់ណាស់ហើយ។ ពួកគាត់ចូលនិវត្តន៍។ បំណងរបស់ខ្ញុំ គឺថា បិតាមានអាយុជិត ៧0 ឆ្នាំហើយគួរគប្បីចម្រើនសមាធិតាមបែបសាសនា។ ប៉ុន្តែ ខ្ញុំជំរុញគាត់ គ្មានប្រយោជន៏សោះ។ គាត់មានតែធ្វើកំប្លែងលេងទៀតផង។ ប្រហែលជាធម្មទេសនារបស់ព្រះតេជគុណ កាសែតនេះអាចធ្វើឱ្យគាត់ភ្ញាក់ខ្លួនបាន។ ដូច្នេះ សូមព្រះតេជគុណសម្តែងឱ្យមានឥទ្ធិពល។

Venerable Sir! Both my Parents are still living but unable to work due to old age. They are in retirement. My wish…Father, nearing 70, should take up religious meditation. But I urge him to no avail. He even makes a joke of it. Maybe your discourse via this tape might make him turn around. So please discourse to that effect.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

ដូចអ្នកទាំងអស់គ្នាបានដឹងហើយ បន្លាគឺជាវត្ថុស្រួចដែលដុះចេញនៅដើមឈើ។ ប៉ុន្តែ មិនមែននៅគ្រប់ប្រភេទឈើនោះទេ។ ខ្ញុំគិតថា វានឹងមិនមែនជាការងាយទេ ក្នុងធ្វើឱ្យដើមឈើនោះដុះនូវបន្លា។ ជាទូទៅ មនុស្សម្នាក់ៗមានអារម្មណ៏សប្បាយរីករាយអំពី

ជីវិតរបស់គាត់ ឬនាង តាមបែបបទ និងឥរិយាបថផ្ទាល់របស់ខ្លួន។ ឥឡូវនេះ អ្នកកំពុងតែប្រឈមមុខជាមួយបិតា ហើយជាជាងចង់ឱ្យគាត់ចម្រើនសមាធិ។ អ្នកស្នើខ្ញុំ ប៉ុន្តែ តើអ្នកណាមួយដែលបិតារបស់អ្នករាប់អានខ្ពស់ ឬគោរពស្រឡាញ់ ឬរាប់ជាមិត្ត?។ អ្នកណាម្នាក់ចំណោមពួកគេអាចយកឈ្នះគាត់បាន ជាជាងយកចិត្តទុកដាក់ស្តាប់ឱវាទរបស់អ្នក។

As known to all, a thorn is something sharp growing in a tree. But not every species of tree. I don’t think it will be easy to make a tree develop thorns. Generally everybody feels happy about his or her life, with own bent and behaviour. Now, you are confronting Father, and would rather have him taking up meditation. You are requesting me, but whom does your father regard highly or respect or make friends with? One of them could win him over to heed your advice.

រឿងនេះ ហេតុអ្វីបិតារបស់អ្នកមិនមានចូលចិត្តសមាធិ?។ តើគាត់មិនដាក់ចិត្តសមាធិឬ?។ ឬក៏បុគ្គលដែលគាត់គោរពរាប់អាន ឬស្រឡាញ់មិនបានផ្តល់យោបល់ពីទម្លាប់នៃការធ្វើសមាធិ?។ នៅទីបំផុត ប្រហែលគិតថា វាអន់ណាស់ក្នុងការស្តាប់សម្តីកូនស្រីរបស់គាត់។ ដើម្បីធ្វើឱ្យគាត់វិវត្តឡើង វាមានតែមេត្តាធមិទេ សម្រាប់បញ្ជាក់ អ្នកគួរតែរក្សាខ្លួនអ្នក ពីព្រោះថា ការស្រឡាញ់លើសលប់ពេកទៅ គំនិតខឹងសម្បារកើតនៅក្នុងចិត្តរបស់អ្នក មានដូចជា “ពុក! ធ្វើអ៊ីចេះ, រស់នៅអ៊ីចេះ, ធ្វើចលនាអ៊ីចេះ, ប៉ុន្តែត្រូវចៀសចេញពីនោះ, ចូររំលឹកអ្នក” ។

This being so, why does not your father feel like meditating? Is he not inclined to do it? Or a person worthy of his regard or affection is not suggesting a habit of meditation yet? Lastly, maybe it is below him to listen to his own daughter. To make him improve--it is your *mettā* for sure, you should restrain yourself because, due to over-enthusiasm some angry thought springs up in you, like, “Father! Do thus, live thus, move thus, but shun that, mind you.”

តាមពិត មេត្តាធមិគឺសម្រាប់សន្តិភាព។ ដូច្នេះ ចូរប្រឹងប្រែងទូន្មានឱ្យអស់ពីសមត្ថភាពរបស់អ្នក ប៉ុន្តែមិនត្រូវជ្រុលហួសហេតុទេណា។ ចូរធ្វើវាដោយប្រពៃ។ ការធ្វើឱ្យនរណាម្នាក់ក្នុងបំណងរបស់អ្នក ត្រូវអមជាមួយដោយការធ្លាក់ចុះនូវមេត្តាធមិ នៅផ្នែកខាងអ្នក។ ចូរកុំធ្វើឱ្យមេត្តាធមិធ្លាក់ចុះ។ ការផ្សាយនូវមេត្តាធមិ គឺមានប្រយោជន៏កាន់តែច្រើនទៅៗ។

In fact, *Mettā* is for peace. Thus, do advice to your utmost, but not to the extreme. Do it

properly. Developing someone in your mould is accompanied by a decrease in *Mettā* on your part. Never let the *Mettā* element decrease. An attribute of *Mettā* is more and more benefit.

លោក **ភូ អោង ប្យូ ទុន** (U Ko Aung Phyo Htun)

ព្រះតេជគុណ! មាតាបិតាបង្គាប់បញ្ជាកូន ពីព្រោះតែសេចក្តីស្រឡាញ់ ខ្ញុំសារភាព។ ប៉ុន្តែ នៅពេលពួកគេនៅជាកូន។ នៅពេលនោះ តើមានអ្វីបញ្ជាក់ថា ពួកគេបានគោរពតាមពាក្យទូន្មានរបស់មាតាបិតារបស់គេទៅ? ។ ខ្ញុំចង់ដឹងបញ្ហានេះ។

Venerable Sir, Parents order Children about because of love, I admit. But they once were Children. At that time, to what extent did they obey their parents' instruction, I would like to know.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

អ្វីដែលអ្នកបានសួរ ត្រូវហើយបុគ្គលម្នាក់ៗអាចជាមាតាបិតា ឬមិនមែនជាមាតាបិតា ប៉ុន្តែ គ្រប់រូបសុទ្ធតែជាកូនប្រុស ឬកូនស្រី។ គ្រប់រូបសុទ្ធតែឆ្លងកាត់កុមារភាព។ តើអ្នកស្រឡាញ់ពុក ឬម៉ែប៉ុណ្ណា? ។ តើអ្នកចម្រើននូវមេត្តាធម៌ចំពោះពួកគាត់ប៉ុណ្ណាដែរ? ។ ចំពោះបញ្ហានេះ តើអ្នកពឹងផ្អែក ឬមានជំនឿលើពួកគាត់ប៉ុណ្ណា? ។ ផ្អែកតាមគុណធម៌ទាំងនេះ តើអ្វីជាទំហំដែលអ្នកជាធម្មតាធ្វើតាមការបញ្ជារបស់ពួកគាត់? ។ វាមានចម្លើយសម្រាប់ឱ្យជាក់ច្បាស់។ មាតាបិតាប្រគល់ការងារមួយ ដែលអ្នកច្បាស់ជាអាចបំពេញបាន ឬមិនអាច ឬថា ដែលអ្នកគួរបំពេញ ឬមិនគួរបំពេញ។ ជាឧទាហរណ៏ អ្វីដែលព្រះបាទសិទ្ធត្ថ ត្រូវបានបង្គាប់បញ្ជាឱ្យអនុវត្ត ដោយព្រះបិតារបស់ព្រះអង្គ ព្រះបាទសុទ្ធោទនៈ មិនគួរបានធ្វើតាមទេ។

What you asked…yes, a person may be a parent or not, but everybody was or is a son/daughter. Everybody pass through a childhood. How much do you love Father, or Mother? How much *Mettā* do you habour towards them? For that matter, how much do you rely on or have faith in them? Based on these qualities, to what extent do you usually do their bidding? There will be an answer for sure. Parents give an assignment, which you would be able to accomplish or not, or which you should or should not accomplish. For example, what Prince Siddhattha was ordered to carry out by his father, King Suddhodhana, should not be complied with.

កូនត្រូវបានប្រឈមនឹងជម្រើស ដូចជា "ខ្ញុំមិនអាចធ្វើតាមការបញ្ជារបស់មាតាបិតាទេ ឬខ្ញុំអាចធ្វើបាន។ ឥឡូវនេះ ចូរព្យាយាម

ធ្វើជាមនុស្សឆ្លាត ជាអ្នកអប់រំល្អ។ ក្រោយមក អ្នកជាកូននឹងដឹងថា តើត្រូវដោះស្រាយជាមួយមាតាបិតាដូចម្ដេចជាមិនខាន។ មិនមានវិធីផ្សេងទៀតនោះទេ ចំពោះរឿងនេះ។ ជាងនេះទៅទៀត ខ្ញុំមានបទពិសោធន៏ផ្ទាល់របស់ខ្ញុំ។ នៅថ្ងៃមួយ បុគ្គលម្នាក់បានសួរខ្ញុំថា តើការទំនាក់ទំនងរបស់ខ្ញុំជាមួយមាតាប្រព្រឹត្តទៅស្នើទេ?។ ខ្ញុំបានឆ្លើយថា "អុំម..., ខ្ញុំមិនដែលបានធ្វើអ្វីមួយឱ្យនាងកើតទុក្ខទេ"។ នៅពេល ខ្ញុំរិះគិតនូវចម្លើយរបស់ខ្ញុំឡើងវិញ ខ្ញុំនឹកឃើញ ខ្ញុំបានធ្វើនាងមិនសប្បាយម្ដងដែរ។ រឿងហ្នឹងវាអ៊ីចេះ ខ្ញុំធ្វើការរកប្រាក់ ហើយពេលល្ងាចឡើង ប្រគល់ប្រាក់ទាំងអស់របស់ខ្ញុំទាំងមួយកាក់មួយសេនដល់មាតា។

Children are faced with choices: like, I cannot do my parents' bidding, or I can do it. Now, try to be clever, well-bred. Then, you Children will come to know how to deal with parents. There is no other way for that. However, I have had my own experience. The other day someone asked me whether my relationship with Mother went smooth. I answered, "Hm, I never did anything to make her sad". When I reconsidered my answer, I found out I saddened her once. It went like this: I was working for money, and in the evening turned over all my money, and every penny at that, to Mother.

បញ្ហាបានកើតឡើង នៅពេលមួយខ្ញុំបានសុំមាតានូវលុយចំនួន ២៥ ខ្ចាត ទៅលេងនូវហាងតែ ជាមួយមិត្តរបស់ខ្ញុំ ដោយឡែក គាត់បានឱ្យខ្ញុំតែ១០ខ្ចាត។ ខ្ញុំមិនយកលុយនឹងទេ ប៉ុន្តែខ្ញុំបានយំ ដោយគិតថា "ខ្ញុំតែងតែប្រគល់នូវចំណូលទាំងអស់របស់ខ្ញុំទៅម៉ែ ហើយប្រព្រឹត្តល្អ។ ប៉ុន្តែ នាងឱ្យខ្ញុំតែ ១០ ខ្ចាត ប៉ុណ្ណោះ ជំនួស ២៥ ខ្ចាត ដែលខ្ញុំបានសុំ"។ តាមធម្មតា ការយំរបស់ខ្ញុំបានធ្វើម៉ែកើតទុក្ខ។ ប្រសិនបើ ខ្ញុំបានយកប្រាក់ ១០ ខ្ចាតនោះ ហើយទប់ទឹកភ្នែករបស់ខ្ញុំនោះមិនមានបញ្ហា សម្រាប់ភាពស្រងោះស្រងោចខាងផ្នែកមាតាដែរ ប៉ុន្តែ ហេតុដ៏អាក្រក់នៅខាងផ្នែករបស់ខ្ញុំ នៅឯហាងតែ។

As it happened, when I asked Mother for 25 kyats to visit the tea shop with my friends, I was given only 10 kyats. I did not take it, but cried my heart out, thinking, "I always give all my income to Mother and behave well. Yet she gives me 10 kyats only instead of 25 I ask for". Naturally my crying saddened Mother. If I had taken the 10 kyats and suppressed my teary inclination, there would have been no cause for gloom on Mother's part, but cause for inconvenience on my part at the tea shop.

ដូច្នេះ បុគ្គលគ្រប់រូបគួរតែឈ្វេងយល់ ថាតើទំហំអ្វីដែលពួកគេអាចប្រព្រឹត្តត្រឹមត្រូវ។ ប៉ុន្តែ ទទួលយក ត្រូវធ្វើជាអ្នកអប់រំល្អសិន។

យើងលក់អុសនៅផ្ទះ។ មាតាបានលក់អុសនោះឱ្យមិត្តភក្ដិរបស់គាត់ចាំឱ្យលុយពេលក្រោយ។ នៅពេលត្រូវការលុយ ម៉ែបានឱ្យខ្ញុំទៅទារប្រាក់ជំពាក់នោះ។ គាត់បាននិយាយថា គាត់មានអារម្មណ៍មិនល្អទេ ដោយទារពួកគេខ្លួនគាត់។ ខ្ញុំមិនបានខឹងនឹងមាតាទេ ប៉ុន្តែ ពេលមួយ ខ្ញុំបានបង្ករឿងជាមួយអតិថិជន សម្រាប់ប្រយោជន៍របស់មាតា។ ក្រោយមកទៀត ម៉ែបានឱ្យខ្ញុំទៅទារលុយដែលជំពាក់ម្ដងទៀត។ ខ្ញុំបានធ្វើពុតក្នុងការគោរពម៉ែ ដើម្បីមិនធ្វើឱ្យនាងកើតទុក្ខទៀត។

So, everyone should find out to what extent they could behave well. But, be inclined to be well-bred first. We sold firewood at home. Mother sold it to her friends for their payment later. When it was due, she sent me off for collection of payments. She said she would feel bad asking for them herself! I was not angry at Mother, but once I picked up a quarrel with a customer for Mother's sake. Then, Mother sent me again to collect the money owed. I pretended to obey Mother so as not to make her displeased.

ខ្ញុំបានជិះកង់ចេញទៅក្រៅ ប៉ុន្តែ ឈប់នៅឯហាងតែមួយស្រ-បក់។ នៅពេលវិលត្រឡប់មកផ្ទះវិញ ខ្ញុំបានពន្យល់ម៉ែថា លុយជំពាក់នោះ គេមិនបានសងទេ។ រឿងនោះទៅជាធម្មតា ចាប់តាំងពីលុយនោះមិនអាចប្រមូលបាន។ នាងមិនបានដឹងការពិត រហូតដល់នាងស្លាប់។ ខ្ញុំបានព្យាយាមធ្វើបែបនេះ ព្រោះមិនចង់ធ្វើឱ្យម៉ែកើតទុក្ខទេ។

I went out riding a bike, but stayed for a proper time at the tea shop. On returning home, I explained to Mother that the required money was not paid. That was not unusual since the money was not collectible. She did not know the truth till her death. Thus I tried so as not to displease Mother.

ទោះជាយ៉ាងណា មានវត្ថុជាច្រើនដែលមិនអាចធ្វើកើតនៅខាងផ្នែកកូន ហើយក៏មានវត្ថុជាច្រើនទៀតដែលកូនមិនអាចបំពេញដើម្បីប្រតិបត្តិតាមបំណងរបស់មាតាបិតា។ ដូច្នេះ ចូរកុំធ្វើឱ្យមាតា ឬ បិតាកើតទុក្ខ។ អ្វីជាច្រើនដែលកូនចង់បានពីមាតាបិតា គឺពិបាកអនុវត្ត ឬមិនប្រពៃ។ សូម្បីតែ នៅពេលបុគ្គលម្នាក់ៗមិនអាចធ្វើឱ្យអ្នកសប្បាយក៏ដោយ អ្នកគប្បីបំពេញកាតព្វកិច្ចតាមដែលអ្នកអាចធ្វើបាន និងឱ្យល្អប្រពៃតាមដែលអ្នកអាចធ្វើបាន។ ប្រសិនបើ មានការយល់គ្នាទៅវិញទៅមករវាងមាតាបិតា និងកូនៗ ភាពលំបាកទំនាក់ទំនងនៅក្នុងគ្រួសារទាំងឡាយថយចុះជាមិនខាន ទោះបីជា

មិនអស់ទាំងស្រុង។ អ្នកគ្រាន់តែគិតគូរថា តើការយល់គ្នាទៅវិញទៅមក នឹងនាំឱ្យល្អដល់កម្រិតណា។ អ្នកយល់ស្រប មិនអ៊ីចឹងឬ?។

However, there is a lot not doable on Children's part, and also a lot which children cannot accomplish to conform to parental wish. Therefore, don't make Mother, or Father, sad. A lot of what Children want in parents are impractical, or improper. Even when everybody cannot be made happy you still should oblige as much as you can, and as properly as you can. If there is mutual understanding between Parents and Children, relationship difficulties in families decrease, if not become extinct completely. Just you reckon how much good mutual understanding will bring about. You agree, don't you?

អ្នកស្រី **មូ មូ** (Daw Mu Mu)

ព្រះធម៌ដើរតួដ៏សំខាន់មួយ ក្នុងបុគ្គលដែលមានវប្បធម៌ ឬក៏មានការអប់រំល្អ។ នៅពេលកូនប្រុសរបស់ខ្ញុំរៀននៅថ្នាក់ទី ៥ ឪពុករបស់គាត់បានស្លាប់ ហើយខ្ញុំបានព្រួយបារម្ភសម្រាប់គាត់។ តើព្រោះហេតុអ្វី?។ ខ្ញុំមានកូនស្រី ហើយពួកគេទាំងអស់គោរពខ្ញុំ។ ប៉ុន្តែកូនប្រុសអាចផ្សេង ជាពិសេស នៅពេលគាត់ចាប់ផ្តើមមានអារម្មណ៍អំពីខ្វះបិតា ដើម្បីគ្រប់គ្រងគាត់។ សំណាងល្អ នៅថ្នាក់ ៩ កូនប្រុសរបស់ខ្ញុំបានចូលរៀនវគ្គសិក្សាទាំងនេះ ដែលធ្វើឱ្យគាត់ចេះគួរសម និងសុភាពរាបសា។

Doctrine plays an important role in one's being cultured or well-bred. When my son was in Grade V his father died, and I deeply feared for him. Why? I have daughters and they obey me mostly. But Son could be different, especially when he starts feeling deeply about lack of a father to control him. Fortunately my son by Grade IX got to attend these courses, which make him polite and gentle.

ឥឡូវនេះ កូនៗនៅទីនេះមានមាតាបិតាផ្សេងៗគ្នា។ យើងជាមាតា ក្នុងការចិញ្ចឹមកូនរបស់យើងត្រូវដឹងចិត្តទម្លាប់ពួកគេ ក៏ដូចជាមិត្តភក្តិ និងគូកនរបស់គេ។ ពេលយើងទៅកាន់ទីជនបទសម្រាប់ការពិភាក្សាស្តីអំពីការលើកស្ទួយក្មេងឱ្យចេះគួរសម និងជាអ្នកអប់-រំល្អ។ យើងបានយល់ដូចជាកូនប្រុសនៅទីនេះ ទើបនិយាយមិញដែរតំបន់ខ្លះ មានមាតាបិតា និងកូនស្រឡាញ់គ្នាទៅវិញទៅមកច្រើនជាងនៅទីក្រុងយ៉ាំងហ្គូន។ ទោះជាយ៉ាងណា មានវគ្គសិក្សា និងកម្មវិធីបែបនេះកាន់តែច្រើន នឹងធ្វើកូនប្រុសស្រីមីយ៉ាន់ម៉ាក្លាយជាកូនដែលមានវប្បធម៌ និងជាកូនមានការអប់រំល្អ។

Now, Children here have different types of parents. We Parents, in bringing up our children, need to know the mind-set of them as well as that of their friends and companions. When we went to the countryside for discussions on raising polite and well-bred children we found, just like a son here said, some areas have parents and children more beloved of one another than in Yangon. Anyhow, more of such courses and programmes will make sons and daughters of Myanmar cultured and well-bred.

លោកវេជ្ជបណ្ឌិត **ណេយ ឡាត** (Dr. Nay Lat)

ព្រះតេជគុណ! អ្នកបាននិយាយរឿងមួយអំពីសត្វឆ្កែ ដែលខ្ញុំចង់បន្ថែម។ ខ្ញុំមានសត្វឆ្កែមួយក្បាលនៅផ្ទះ។ វាដូចជាកូនបង្កើតរបស់ខ្ញុំដែរ។ ប៉ុន្តែ ខ្ញុំជាម្ចាស់ដែលផ្គាប់ផ្គុន ដើម្បីធ្វើឱ្យឆ្កែនេះធ្វើអាក្រក់។ ជាការពិត វាអាក្រក់ ហើយចាប់ផ្តើមខាំខ្ញុំ។ នៅពេលខ្ញុំពិគ្រោះយោបល់ជាមួយមិត្តរបស់ខ្ញុំ ដែលជាអ្នកអាចមានចំណេះខាងសត្វឆ្កែ គាត់បានឆ្លើយតបថា "សត្វឆ្កែមិនដែលខាំម្ចាស់របស់វាទេ។ ហេតុផលចំពោះការធ្វើអាក្រក់របស់វា គឺការហ្វឹកហាត់។ គ្រូបង្វឹកត្រូវទទួលខុសត្រូវចំពោះវា ប្រហែលជាអ្នកគ្មានជំនាញ"។

Venerable Sir, you said something about the dog which I would like to add to. I have a pet dog get home. It is just like my own child to me. But, I might have been too indulgent a master to make my dog act bad. In fact, it grows worse, and starts biting me. When I consulted my friend who is knowledgeable dogs, he replied, "A dog never bites its master. Reason for its acting bad is training. The trainer is responsible for it; perhaps you are unskilled."

ដូច្នេះ គំនិតនេះបានប៉ះទង្គិចរូបខ្ញុំ ទាក់ទងនឹងមាតាបិតា។ អ្នកចង់បាននូវអ្វីដែលយើងសមនឹងទទួលបានក្នុងបញ្ហានៃកូន។ ទោះបីជាយ៉ាងណា ខ្ញុំចង់និយាយទាំងសងខាង។ យើងគួរងាកទៅមើលគុណវិបត្តិរបស់មាតាបិតា ហើយមានជំនឿក្នុងមេត្តាធម៌របស់ពួកគេចំពោះយើង។ នៅផ្នែកខាងមាតាបិតា អ្នកគួរពិចារណាថា កូនមិនមែនមានអាកប្បកិរិយាអាក្រក់ដោយខ្លួនតែម្នាក់ឯងទេ ហើយរំលឹកឡើងវិញថា តើអ្នកកំពុងបង្វឹកពួកគេរបៀបណា។ អរគុណព្រះ-តេជគុណ។

Thus a thought struck me, concerning Parents. You get what we deserve in the matter of children. However, I would like to address both sides. We should turn to parental faults and have faith in their loving-kindness towards us. As for Parents' side, you should consider that Children do not misbehave by themselves only, and review how you are training them. Thanks, Venerable Sir.

លោក **ម៉ាឃ្ក សាំង ជំរ ស៊ិន ប្យូ** (U Mg Saing Kyaw Zin Phyo)

មាតាបិតាតែងតែមានមេត្តាធម៌ចំពោះកូន ប៉ុន្តែពួកគេនិយាយថា ពួកគេមានសេចក្តីព្រួយបារម្ភដោយសារកូន។ នៅពេលណាមួយ កូនត្រូវព្រួយបារម្ភអំពីមាតាបិតាវិញ។ នៅជាយុវជន យើងមិនត្រូវមានអាកប្បកិរិយាអាក្រក់ទេ ព្រោះវាជាពេលត្រូវថែរក្សាមាតាបិតា។ ចំពោះបញ្ហានេះ យើងចង់ឃើញមាតាបិតាមានសុខភាពល្អ និងមិនទទួលការស្តីបន្ទោសពីអ្នកដទៃ។ ពេលយើងតបគុណទាំងនេះចំពោះមាតាបិតា ពាក្យពេចន៍របស់យើងគឺត្រូវបដិសេធចោល។ ហេតុអ្វីអ្នកមិនព្យាយាមអត់ធ្មត់ រហូតដល់អ្នកទទួលជោគជ័យ?។ មិនមានផ្លូវទេ ពីព្រោះមាតាបិតា គឺជាមាតាបិតា រីឯកូនគឺជាកូន។ យើងព្យាយាមពន្យល់ ហើយពួកគាត់ចាប់ផ្តើមស្វែងរកវិធីផ្សេងទៀត។ មិនមានអ្វីទៀតទេ ព្រះតេជគុណ។

Parents harbor *Mettā* towards Children, yet they say they have worries because of Children. But, once in a while, Children get to worry about parents. As young adults we need not be misbehaved because it is time to look after our parents. For this we would like to see Parents conducting themselves in good health and not inviting blame from others. When we voice these to parents our advice is rejected. Why not try patiently till you succeed, Son? No way, because parents are parents and children are children. We try to explain and they start looking the other way. That is all, Venerable Sir.

ព្រះតេជគុណបណ្ឌិត **ចេកិន្ទ** (Ven. Dr. Chekinda)

មាតាបិតាគួរគប្បីបង្រៀនដូច្នោះហើយ។ កូនមិនដែលប្រព្រឹត្តអាក្រក់ទេ វាគ្រាន់តែយល់មិនគ្រប់គ្រាន់ប៉ុណ្ណោះ។ វាជាអាជ្ញាបញ្ជាដែលថា មាតាបិតាធ្វើឱ្យកូនជឿទុកចិត្ត និងដោយបញ្ចុះបញ្ចូលនូវបញ្ហានោះ។ វានឹងដូចជាការចាក់ទឹកទៅលើដីខ្សាច់អ៊ីចឹង ថែមទាំងកាន់តែអាក្រក់ទៅទៀត ប្រសិនបើ កូនមិនធ្វើតាមដោយពេញចិត្ត។ មាតាបិតាតែងតែព្រួយបារម្ភថា លុះត្រាតែគាត់ ឬនាងបង្រៀនកូនដោយវាចា ទើបកូននឹងក្លាយជាមនុស្សមានអាកប្បកិរិយាអាក្រក់មិនចេះគួរសម ឬក៏ឈ្លើយ។ ដូច្នេះ ជំនឿ... ជឿលើខ្លួនឯង និងជឿលើកូនគួរតែចម្រើនឡើង។ ឥឡូវនេះ កូន...ចូរអ្នកកុំភ្លេចគោរពមាតាបិតារបស់អ្នក។

Parents should teach thus. A child never acts bad; it just does not know enough. It is imperative that parents convince children, and persuasively at that. It will be like pouring water onto the sand, or worse, if Children are not favourably inclined. A parent often worries that unless he/she verbally teaches a child, the latter will be

misbehaved, impolite, or awkward. Thus, confidence-self-confidence and confidence in children should be cultivated. Now Children-never ever disobey your Parents.

គេប្រាប់ឱ្យអ្នកទាំងអស់ធ្វើ មិនដែលគេចចេញពីវាឬ។ ចូរកុំគិតថា មាតាបិតាជាមនុស្សគួរឱ្យខ្លាច។ ប្រសិនបើមិនដូច្នេះទេ អ្នកនឹងមានតែបដិសេធពាក្យទូន្មានរបស់ពួកគេ។ រឿងនេះ គឺត្រូវយល់ទាំងមាតាបិតា និងកូន។ ពិតហើយ អ្វីដែលកូនប្រុសទើបតែនិយាយមិញថា អ្នកទទួលនូវអ្វីដែលអ្នកសមនឹងទទួលប៉ុណ្ណោះនោះ គឺត្រឹមត្រូវ។ ខ្ញុំមិនមានន័យថា អ្នកមិនព្រមទទួលនោះទេ ព្រោះអ្នកបានធ្វើអាកប្បកិរិយាអាក្រក់ ឬអ្នកគួរបានថ្កុំថ្កើង ប្រសិនបើ អ្នកបានប្រព្រឹត្តល្អ។ សូម្បីតែអ្នកបានប្រព្រឹត្តអាក្រក់ តើនៅពេលណា?។ អ្នកមិនអាចដឹងទេ។

Do all you are told to do, never shunning it. Never ever think Parents are to be afraid of. If not, you will only get to reject their admonition. This is to be understood by both Parents and Children. Really, what a son just said, you get only what you deserve, is true. I do not mean you decline now because you had acted bad; or you would prosper if you had acted good. Even if you had acted bad, what time was it? You cannot know that.

ឬក៏នៅក្នុងជាតិនេះ មាតាបិតារបស់អ្នកថ្កុំថ្កើងពេក ដែលពួកគេធ្វើបុណ្យកុសល ដូចជាការកសាងចេតិយ និងវត្តអារាម។ ប៉ុន្តែពួកគេនៅតែអាចមានកូនប្រុសពាល ឬកូនស្រីពាលដែរ។ ស្ថានភាពនេះ គួរតែឃើញនូវក្នុងពន្លឺដូចគ្នា អ្នកចង់បាននូវអ្វីដែលអ្នកសមនឹងទទួល។ ជាក់ស្តែង មាតាបិតាខ្លះជាអ្នកប្រើគ្រឿងស្រវឹង ប៉ុន្តែកូនរបស់គេមានអាកប្បកិរិយាល្អ ដែលពួកគេស្អប់គ្រឿងស្រវឹង និងគ្មានអារម្មណ៍នឹងល្បែង។ បែបនេះហើយជាមាគ៌ាលោកីយ៍នោះ។ យើងជឿថា យើងកើតមករស់នៅជាមួយគ្នាក្នុងជាតិនេះ ព្រោះតែយើងមានការប្រព្រឹត្តិ (កម្ម) ស្រដៀងគ្នានៅក្នុងជាតិមុន។

Or in this existence your Parents are so prosperous that they get to perform meritorious deeds like building pagodas and monasteries. Yet they still could have fools of a son or a daughter. This situation should be seen in the same light-you get to attain what you deserve. In reserve, some parents are alcoholics, but their children are so well-behaved that they hate intoxicating drinks and take no interest in gambling. Such could be the worldly ways. We believe we get to live together in this life because of our similar *kamma*-actions in the past existence.

វាមិនអាចជាអ្វីផ្សេងឡើយ។ ដូច្នេះ អ្នកទទួលនូវអ្វីដែលគួរសមរម្យ មានប្រយោជន៍ ឬអាចរស់នៅជាមួយគ្នាបាន។ មាតាបិតា និងកូន ជាមនុស្សមានវប្បធម៌ ជាមនុស្សចេះគួរសម ឬក៏មាតាបិតា និងកូន ជាមនុស្សពេញដោយសកម្មភាព គួរឱ្យស្តីបន្ទោស បញ្ហាប្រ-ភេទនេះ នៅតែដំណើរការរលូនក្នុងករណីទាំងឡាយ។ ពេលមាតាបិតាជាមនុស្សសប្បុរស ហើយកូនជាមនុស្សពាល ក៏វានៅតែប្រ-សើរ។ តើព្រោះហេតុអ្វី?។ មាតាបិតាល្អពិតណាស់នឹងធ្វើកូនរបស់គេឱ្យមានអាកប្បកិរិយាល្អប្រពៃ។ ហើយករណីរក្សាទុកក៏អាចជាកិច្ចការល្អប្រពៃដែរ។ ដូច្នេះ ខ្ញុំនិយាយថា "ចូរអ្នកជាមាតាបិតា និងកូនកុំជេរស្តីបន្ទោសគ្នាទៅវិញទៅមក ប៉ុន្តែ ត្រូវបំពេញនូវភាពខ្លាំងឱ្យគ្នាទៅវិញទៅមក ប្រសិនបើចាំបាច់"។

It cannot be otherwise. Thus you get what are suited to, worthy of, or able to live with. Both Parents and Children are cultured and polite, or both Parents and Children are full of blameworthy actions- still it is sort of running smooth in the cases. When Parents are meritorious and Children are foolish, it is even better. Why? The good Parents will surely make their Children behave properly. And the reserve case could also be functioning well. Therefore, I say: Do you Parents and Children not blame one another, but only complement one another's strength, if necessary".

ទាក់ទិនការស្វែងរកស្តីបន្ទោស តើបុគ្គលម្នាក់ៗអាចអើពើនូវអំពើគួរស្តីបន្ទោស ដែលកំពុងតែដំណើរការនៅពីមុខភ្នែករបស់ខ្លួនដោយរបៀបណា?។ ប្រសិនបើ អ្នកទាំងអស់គ្នាមិនចង់ឱ្យកើតឡើងនូវទង្វើដែលគួរស្តីបន្ទោស កូន ឬមាតាបិតាត្រូវវៀរចាកពីការប្រព្រឹត្តអាក្រក់។ ប្រសិនបើ ធម្មជាតិមានពីកំណើតរបស់អ្នកមានការលើកតម្កើងតិចតួច អ្នកគួរគប្បីនៅតែបន្តធ្វើល្អ គាំទ្រ និងកែតម្រូវគ្នាទៅវិញទៅមក។ បំណងធំនៃកម្មវិធីនេះ គឺជាគ្រួសារដែលកិច្ចការល្អ។ តើមានអ្វីត្រូវធ្វើទៀត ក្នុងការបែងចែកព្រំដែនមាតាបិតាពីកូននោះ?។ ចូររលាស់វាចោលឱ្យអស់ទៅ ដែលដូចជាការសរុបទាំងអស់ក្នុងពិភពលោកខាងក្រៅដែរ។

In regard of blame-finding, how could one ignore a blameworthy action in progress before one's eyes? If you do not want to appear blameworthy, Children, or Parents, just have to refrain from acting bad. If your innate nature is short of praise, still you would well carry on, supporting and correcting one another. The main theme of this programme is the well-functioning family. What to do with the boundary separating Parents from Children? Get rid of it, which is like globalization in the outside world.

ការយល់ពីធម្មជាតិរបស់បុគ្គលដទៃ តម្រូវឱ្យលះបង់ចោលនូវឧបសគ្គគ្មានប្រយោជន៏ទាំងឡាយ។ ប្រសិនបើ ធ្វើដូច្នេះកើត នោះកូនក៏ធ្វើល្អ ហើយមាតាបិតាក៏ធ្វើល្អ។ ប៉ុន្តែ ដំណើរការគួរតែទៅតាមលំដាប់លំដោយ។ ការធ្វើឱ្យកើតមានការប្រែប្រួលភ្លាមៗ នឹងជាមហាចង្រៃ។ ការយល់អ្នកដទៃដោយសន្សឹមៗ នឹងនាំមកនូវការទំនាក់ទំនងរលូន និងសាមគ្គី។ យើងនៅមានពេលតែមួយភ្លែតទៀតត្រូវនិយាយ។ ដូច្នេះ មាតាបិតា កូនប្រុស កូនស្រី សូមបំពេញកិច្ចការល្អចំពោះគ្នាទៅវិញទៅមក។

Understanding the other's nature requires getting rid of all useless obstacles. If so, Children will do well, and Parents will do well. But the process should be gradual. Bringing about a sudden change will be disastrous. Gradually understanding others will lead to smooth relationship and harmony. We exist just for a while, so to speak. As such, Mother, Father, Son, or Daughter may do well obliging one another.

ចំពោះកិច្ចការដែលរលូនរបស់គ្រួសារ អ្នកត្រូវបំពេញកាតព្វ-កិច្ចឱ្យល្អចំពោះមាតាបិតា។ ចូរប្រឹងប្រែងរៀនសូត្រ ដើម្បីបង្កើននូវចំណេះដឹងរបស់អ្នក ត្រូវគោរពថ្វាយបង្គំគ្រូដើម និងលោកគ្រូអ្នកក្នុងភាពសម្បូណ៌។ ចូរលេង និងបរិភោគអាហារឱ្យទៀតទាត់ ប៉ុន្តែអ្នកគួរចេញលំហែកាយខាងក្រៅ តាមសមគួរផងដែរ។ មាតាបិតាយាយតា ជួនកាលផ្តល់នូវសេចក្តីសប្បាយរីករាយធំធេងណាស់ដល់កូន។ ការរីករាយទាំងអស់គ្នា មានន័យថា រីករាយរកគ្នាទៅវិញទៅមក អ្នកនឹងសប្បាយរីករាយកាន់តែច្រើនឡើង ហើយអ្នកនឹងធ្វើឱ្យខ្វល់ជាមួយសេចក្តីសុខនេះឯង។ ត្រូវហើយ ការប្រព្រឹត្តិតាមឱ-វាទដ៏ល្អ គឺប្រពៃណាស់។

For the family's smooth functioning, To parents you may well be obliging. Study hard to enhance your intelligence, While paying respect to forebears and teachers in abundance. Play or take meals regularly, But you should go out for fun properly. Parents, grandpa and grandma, On children you may sometimes heap favours. Pleasing by all means one another, Happy you will be further; And with pleasure you will bother. Well, adhering to good advice is paramount.

ទោះជាយ៉ាងណា សកម្មភាពសិក្សាដ៏មហិមាមួយនេះ គឺថា វានឹងមិនមានប្រយោជន៏ បើមិនប្រតិបត្តិតាមទេនោះ។ ដូច្នេះ បន្ទាប់ពីអ្នកបានឱ្យតម្លៃកម្មវិធីនេះ សូមអ្នកទាំងអស់គ្នាឱ្យតម្លៃពាក្យសម្តីរបស់អ្នក និងអ្នកដទៃផ្សេងទៀត ហើយសូមឱ្យក្លាយជាមាតាបិតាល្អ និងកូនប្រុស កូនស្រីល្អ។

សាធុ! សាធុ! សាធុ!

However grand a course of action is, it will come to nothing without compliance. So, after you have appreciated this programme, may you value your words and those of others and become good parents and Sons and Daughters.
Sadhu-Sadhu-Sadhu

ជារឿយៗ ពុទ្ធសាសនិកទាំងឡាយពោលសំដៅចំពោះស្ថាន-ភាពនេះ មានដូចជាៈ-

ក. ប្រថពី និងស្លឹកឫស្សី

ខ. ភ្នំព្រះសុមេរុំ និងស្នែងគោ

គ. សាកលលោក និងភ្នែកម្ជុល

ឃ. មហាសមុទ្រ និងដំណក់ទឹកភ្លៀង

Buddhists often refer to this situation like:

a- Earth and a bamboo leaf,
b- Mount Meru and a bull's horn,
c- The Universe and the eye of a needle,
d- An ocean and a raindrop,

បុត្តទារសង្គហមង្គលនិយាយថា កូនប្រុស កូនស្រីមានបីប្រ-ភេទគឺៈ-

ក. អតិជាតៈ - កូនដែលមានសីល សមាធិ និងបញ្ញា ខ្ពង់ខ្ពស់ជាងមាតាបិតា,

ខ. អនុជាតៈ - កូនដែលមានសីល សមាធិ និងបញ្ញា ស្មើនឹងមាតាបិតា,

ឃ. អវជាតៈ- កូនដែលមានសីល សមាធិ និងបញ្ញា ទាបជាងមាតាបិតា។

Puttadārasaṅgaha maṅgala says there are three kinds of Sons and Daughters.

They are:

a- Atijāta
Children who are higher in morality, concentration and knowledge than Parents,

b- Anujāta
Children who are equal to parents in morality, concentration and knowledge

c- Avajāta
Children who are lower in morality, concentration and knowledge than Parents.